ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២១ លេខ៤១ ត្រីមាសទី០២ ឆ្នាំ២០២១

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារធាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១១-ឧ-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០ឧ២១/៥៧៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ជីថៃអ៊ុតធិកន ឡឺស្រ៊ីត (CHITAITTHIKON LOESRIT)** ជនជាតិថៃ សញ្ជាតិថៃ	៤៩៧៥
១១-ឧ-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០ឧ២១/៥ឧ០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **យ៉ៀក លី (YE LI)** ជនជាតិចិន សញ្ជាតិចិន	៤៩៧៦
១២-ឧ-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០ឧ២១/៥ឧ១ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម ឧត្តមសេនីយ៍ឯក **ឥត្យ ច័ន្ទគីរី** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក	៤៩៧៧
១២-ឧ-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០ឧ២១/៥ឧ២ ស្តីពី ការតែងតាំងមុខតំណែងបន្ថែមឯកឧត្តម **ង្រុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ	៤៩៧ឧ
១២-ឧ-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០ឧ២១/៥ឧ៣ ស្តីពី ការតែងតាំងមុខតំណែងឯកឧត្តម **សេង ម៉ាឆោឫទ្ធិ** ជាអគ្គនាយកនៃអគ្គនាយកដ្ឋានរាជកិច្ច និងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី	៤៩៧៩
១២-ឧ-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០ឧ២១/៥ឧ៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **លូ ជាយូ (LU CHIA-JUI)** ជនជាតិចិន សញ្ជាតិចិន (តៃវ៉ាន់)	៤៩ឧ០
១៣-ឧ-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០ឧ២១/៥ឧ៥ ស្តីពី ការតែងតាំងមុខតំណែងឯកឧត្តម **ប៉ែន រ័ត្ន** ជាអនុរដ្ឋលេខាធិការ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	៤៩ឧ១
១៣-ឧ-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០ឧ២១/៥ឧ៦ ស្តីពី ការផ្ទេរ និងតែងតាំងមុខតំណែងឯកឧត្តម **ការ ច័ន្ទមេត្តា** និងតែងតាំងមុខតំណែងឯកឧត្តម **ស៊ឹម ស៊ីថា** ជារដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍	៤៩ឧ២
១៤-ឧ-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០ឧ២១/៥ឧ៧ ស្តីពី ការផ្តល់នីតិសម្បទាឡើងវិញឱ្យឈ្មោះ **ឃីម ឡាគី** ភេទប្រុស ត្រូវបានហាមឃាត់មិនឱ្យធ្វើនយោបាយសម្រាប់រយៈពេល ៥ (ប្រាំ)ឆ្នាំ	៤៩ឧ៣

១៤-៨-២០២១	-ព្រះរាជក្រឹត្យ នស/រកត/០៨២១/៥៨៨ ស្តីពី ការផ្តល់នីតិសម្បទាឡើងវិញឱ្យឈ្មោះ **ម៉ៅ សុផល** ភេទប្រុស ត្រូវបានហាមឃាត់មិនឱ្យធ្វើនយោបាយសម្រាប់រយៈពេល ៥ (ប្រាំ)ឆ្នាំ	៤៩៨៤

II~រាជរដ្ឋាភិបាល

១~អនុក្រឹត្យ

១៤-៧-២០២១	-អនុក្រឹត្យលេខ ១១៣ អនក្រ.បក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពក្រោមឱវាទរបស់អាជ្ញាធរសៅហ៊ិរញ្ញវត្ថុមិនមែនធនាគារ	៤៩៨៥
១០-៨-២០២១	-អនុក្រឹត្យលេខ ១៣៤ អនក្រ.បក ស្តីពី ការកែសម្រួលរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់អង្គភាពចំណុះក្រសួងមុខងារសាធារណៈ	៥០៣០
១០-៨-២០២១	-អនុក្រឹត្យលេខ ១៣៥ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា	៥០៤៩
៦-៨-២០២១	-អនុក្រឹត្យលេខ ៣៦៩ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ	៥០៥១
៦-៨-២០២១	-អនុក្រឹត្យលេខ ៣៧០ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ	៥០៥៣
៩-៨-២០២១	-អនុក្រឹត្យលេខ ៣៧១ អនក្រ.តត ស្តីពី ការដាក់មន្ត្រីពន្ធនាគារឱ្យចូលនិវត្តន៍	៥០៥៥
៩-៨-២០២១	-អនុក្រឹត្យលេខ ៣៧២ អនក្រ.តត ស្តីពី ការនិយ័តកម្មក្របខ័ណ្ឌ តម្លើងឋានន្តរស័ក្តិ និងថ្នាក់ជូនមន្ត្រីរាជការ	៥០៥៧
១០-៨-២០២១	-អនុក្រឹត្យលេខ ៣៧៣ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា	៥០៥៩

២~សេចក្តីសម្រេច

១៧-៨-២០២១	-សេចក្តីសម្រេចលេខ ៨៦ សសរ ស្តីពី ការផ្លាស់ប្តូរ និងបំពេញបន្ថែមសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តស្វាយរៀង ខេត្តកំពង់ឆ្នាំង ខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ និងខេត្តកោះកុង ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា	៥០៦០

III~ការងារបណ្តាក្រសួង

១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៣-៦-២០២១	-ប្រកាសអន្តរក្រសួងលេខ ៣៣៨ សហវ.ប្រក ស្តីពី នីតិវិធីពិន័យអន្តរការណ៍ លើអំពើល្មើសនឹងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់	៥០៦២
៣-៦-២០២១	-ប្រកាសអន្តរក្រសួងលេខ ៣៣៩ សហវ.ប្រក ស្តីពី ការបែងចែកចំណូលពីការពិន័យអន្តរការណ៍ និងការពិន័យជាប្រាក់លើអំពើល្មើសនឹងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់	៥០៦៧

ក

២~ទីស្តីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល

៦-៤-២០២០	-ប្រកាសលេខ ០១២៧ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្តានីយប្រេងឥន្ធនៈលេខ ០១២៧ រថ.អប្រក.លអ ចុះថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០២០	៥០៧១
៦-៤-២០២០	-ប្រកាសលេខ ០១២៨ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្តានីយរួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០១២៨ រថ.អប្រក.លអ ចុះថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០២០	៥០៧៥
៨-៤-២០២០	-ប្រកាសលេខ ០១៣០ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្តានីយប្រេងឥន្ធនៈលេខ ០១៣០ រថ.អប្រក.លអ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០២០	៥០៧៩
៨-៤-២០២០	-ប្រកាសលេខ ០១៣១ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្តានីយរួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០១៣១ រថ.អប្រក.លអ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០២០	៥០៨៣
៨-៤-២០២០	-ប្រកាសលេខ ០១៣២ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្តានីយប្រេងឥន្ធនៈលេខ ០១៣២ រថ.អប្រក.លអ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០២០	៥០៨៧
៨-៤-២០២០	-ប្រកាសលេខ ០១៣៣ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្តានីយរួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០១៣៣ រថ.អប្រក.លអ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០២០	៥០៩១
២៣-៤-២០២០	-ប្រកាសលេខ ០១៤៤ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្តានីយប្រេងឥន្ធនៈលេខ ០១៤៤ រថ.អប្រក.លអ ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០២០	៥០៩៥

ព្រះរាជក្រឹត្យ

នស/រកត/០៨២១/ ៤៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សហានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិត្រ្តាធរាមហាអ្ឃត្រ
ខេមរាជនា សម្ងហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុតមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយបេស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ជីថៃអ៊ីតធិកន ឡឺស្រ៊ីត** (CHITAITTHIKON LOESRIT) ជនជាតិ **ថៃ** សញ្ជាតិ **ថៃ** កើតនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៨៤ នៅខេត្តខាន់ចាណាប៊ូរី ព្រះរាជាណាចក្រថៃ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ការគ. ២១០៧. ៤៧៩

នស៊ីហមុនី

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០២១

បានចុះហត្ថលេខាត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលមន្ត្រីត ប៊ិន ឈិន

ព្រះរាជក្រឹត្យ

នស/រកត/០៨២១/ ៤៨០

យើង

ព្រះអរុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតូមិជាតិសាសនា អ្នតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិត្រ្តាធរមហាក្សត្រ
ខេមរាជនា សម្ភូហោតាស អម្ពុជឯករាជរដ្ឋប្ញុរណាសន្តិ សុតមង្គលា សិរីមិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មជូនលោក **យ៉េវ៉ែក លី** (YE LI) ជនជាតិ ចិន សញ្ជាតិ ចិន កើតនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៨៥ នៅខេត្តហ៊ូប៉ី សាធារណរដ្ឋប្រជាមានិតចិន។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០២១

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកអចិន្ត្រៃយ៍នៃគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ចិន ឈិន

ព្រះរាជក្រឹត្យ

ន.ស/រកត/០៨២១/៤៥១ យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្ងានតូមិជាតិសាសនា អ្នតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ងហោតាស អម្ពុជឯករាជរដ្ឋបូរណសន្តិ សុតមន្តលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំង និងផ្តល់ឋានៈ ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឆិត្យ ចំរើនភីរ** អគ្គលេខ ១០៩៩៩ ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើអគ្គនាយក។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០២១

នរោត្តម សីហមុនី

បានចុះហត្ថលេខាត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

ព្រះរាជក្រឹត្យ

នស/រកត/០៨២១/ ៤៨៤ យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្ងានតូមិជាតិសាសនា រក្សាខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិឫទ្ធានុភាពមហាក្សត្រ
ខេមរាជនា សម្ងហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុតមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- ព្រះរាជក្រឹត្យលេខ នស/រកត/០៦២១/៤៤៩ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: តែងតាំងមុខតំណែងបន្ថែម ឯកឧត្តម **ង្វៀ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ។

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០២១

ន.ស.ហមុនី

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកការិយាល័យគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ជិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/០៨២១/ ៤៨៣

យើង

ព្រះអរុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហាមុនី
សម្ងានភូមិជាតិសាសនា អ្នកខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិត្រ្តាធរាមហាកប្បក្រ
ខេមរាជនា សម្ងហោតាស អម្ពុជឯករាជរដ្ឋបូរណាសន្តិ សុតមទ្ធលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងមុខតំណែងឯកឧត្តម **សេង ម៉ាឡោម្ហឆ្ង** ជាអគ្គនាយកនៃអគ្គនាយកដ្ឋានរាជកិច្ច និងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើ ថ្ងៃ ២០ ខែ ៤ ឆ្នាំ ២០២១

នរោត្តម សីហមុនី

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០២១

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ជិន ឈិន**

ព្រះរាជក្រឹត្យ

ន.ស/រកត/០៨២១/៤៤៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតូមិជាតិសាសនា អ្នតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាអ្ឃ្រ
ខេមរាជនា សម្ងហោតាស អម្ពុជឯករាជរដ្ឋបូរណាសន្តិ សុតមន្តលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ឈូ ជាយូ** (LU CHIA-JUI) ជនជាតិ **ចិន** សញ្ជាតិ **ចិន(តៃវ៉ាន់)** កើតនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៧៨ នៅទីក្រុងថាវយៀន សាធារណរដ្ឋចិន។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ន.ស.ជ.២០៥.៤៤៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០២១

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមប្រាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ចិន ឈិន**

ព្រះរាជក្រឹត្យ

ន.ស/រកត/០៨២១/៤៧៤ យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្ងានត្ងមិជាតិសាសនា រក្ខតខត្តិយា ខេមរាវដ្ឋរាស្ត្រ ពុទ្ធិវ្រ្ទាធរាមហាអ្ងគ្រ
ខេមរាជនា សម្ងហោតាស កម្ពុជឯករាជវដ្ឋបូរណាសន្តិ សុតមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១: តែងតាំងមុខតំណែងឯកឧត្តម **បែន រ័ត្ន** ជាអនុរដ្ឋលេខាធិការ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ន សីហមុនី

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០២១

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកអចិន្ត្រៃយ៍នៃគណៈរដ្ឋមន្ត្រី

កិត្តិនីតិសោភ័ណ្ឌិត ប៊ិន ឈិន

ព្រះរាជក្រឹត្យ

ន.ស/រកត/០៨២១/៤៤៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្ងានភូមិជាតិសាសនា ក្នុងឋានៈជាព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជា ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ងហោតាស កម្ពុជឯករាជរដ្ឋបូរណាសន្តិ សុតមន្តលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្ទេរ និងតែងតាំងមុខតំណែង ឯកឧត្តម **ភាន ច័ន្ទមេត្តា** ពីរដ្ឋលេខាធិការ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មកជា រដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

មាត្រា២ : តែងតាំងមុខតំណែងឯកឧត្តម **ស៊ឹម ស៊ីថា** ជារដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

មាត្រា៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០២១

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៨២១/ ៥៤៧

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្ងានតូមិជាតិសាសនា អ្នកគង្គិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិវ្រ្ទាធរាមហាក្សត្រ
ខេមរាជនា សម្ងហោតាស កម្ពុជឯករាជរដ្ឋបូរណាសន្តិ សុតមន្តណា សិរីវិបុលា
ខេមរាត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៧/០០៣ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៧ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ដែលប្រកាសឲ្យច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១១៩/០០១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ៤៥ ថ្មី (ស្នូន) នៃច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ក្រោស់បង្គាប់

មាត្រា ១ : ត្រូវបានផ្តល់នីតិសម្បទាឡើងវិញឲ្យឈ្មោះ **យឹម ឌ្យាគី** ភេទ ប្រុស កើតថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៧៥ ដែលត្រូវបានហាមឃាត់មិនឲ្យធ្វើសកម្មភាពនយោបាយសម្រាប់រយៈពេល៥ (ប្រាំ) ឆ្នាំ តាមអំណាចសាលដីកាលេខ: ៣៤០(ឆ) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់តុលាការកំពូល។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០២១

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

ព្រះរាជក្រឹត្យ

នស/រកត/០៨២១/ ៥៤៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្ងានភូមិជាតិសាសនា អ្នកខត្តិយា ខេមរាដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ
ខេមរាជនា សម្ងហោតាស អគ្គជ័យរាជដ្ឋបូរណសន្តិ សុតមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ឆ្លងមន្ទុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៧/០០៣ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៧ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ដែលប្រកាសឲ្យច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១១៩/០០១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៤៥ថ្មី (ស្នូន) នៃច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានផ្តល់នីតិសម្បទាឡើងវិញឲ្យឈ្មោះ **ម៉ៅ សុផល** ភេទ ប្រុស កើតថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៦៣ ដែលត្រូវបានហាមឃាត់មិនឲ្យធ្វើសកម្មភាពនយោបាយសម្រាប់រយៈពេល៥ (ប្រាំ) ឆ្នាំ តាមអំណាចសាលដីកាលេខ: ៣៤០(ឆ) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់តុលាការកំពូល។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០២១

នរោត្តម សីហមុនី

បានបង្ហាញត្រឹមត្រូវតាមច្បាប់ជើម
ប្រធានការិយាល័យរដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ចិន ឈិន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១១៣.អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៤២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៧
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយនិងការជូនដំណឹងមូលបត្រមហាជន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម

- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបរធនបាលកិច្ច
- បានឃើញអនុក្រឹត្យលេខ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១០៧ អនក្រ.បក ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១ ស្តីពីឯកសណ្ឋាន សញ្ញាសក្តិនិងសញ្ញាសម្គាល់របស់មន្ត្រី ភ្នាក់ងារនគរបាលយុត្តិធម៌នៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះ មានគោលដៅកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ សរសេរកាត់ថា **អ.ស.ហ.**។

មាត្រា ២.-

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះអង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.** រួមមាន អគ្គលេខាធិការដ្ឋាន និយ័តករធានារ៉ាប់រងកម្ពុជា និយ័តករមូលបត្រកម្ពុជា និយ័តករសន្តិសុខសង្គម និយ័តកររបបធនបាលកិច្ច និយ័តករគណនេយ្យនិងសវនកម្ម និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ និងអង្គភាពសវនកម្មផ្ទៃក្នុង។

ជំពូកទី២

អគ្គលេខាធិការដ្ឋាន នៃ អ.ស.ហ.

មាត្រា ៣.-

អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** (ហៅកាត់ថា អគ្គលេខាធិការដ្ឋាន) បំពេញមុខងារជាសេនាធិការឱ្យ **អ.ស.ហ.**។ អគ្គលេខាធិការដ្ឋាន មានតួនាទីនិងភារកិច្ចដូចខាងក្រោម÷

- ផ្តល់ការគាំទ្រដល់កិច្ចដំណើរការរបស់ **អ.ស.ហ.**
- សម្របសម្រួល រៀបចំ និងអនុវត្តនូវគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមទាំងបច្ចេកវិទ្យាហិរញ្ញវត្ថុ

- រៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមទាំងតាមដាន និងវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្ត
- សម្របសម្រួលការស្នើសុំការអនុម័តបទប្បញ្ញត្តិ វិធាន និងនីតិវិធីចាំបាច់សម្រាប់ការគ្រប់គ្រងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមទាំងតាមដាន និងវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្ត
- ផ្តល់ការសម្របសម្រួលរវាងនិយ័តករ និងក្នុងក្របខ័ណ្ឌគណៈកម្មការជំនាញ ឬក្រុមការងារបច្ចេកទេស ឬយន្តការអន្តរក្រសួង/ស្ថាប័ន ក្នុងការអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- សម្របសម្រួលកិច្ចសហប្រតិបត្តិការតំបន់និងអន្តរជាតិ រួមទាំងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍
- សម្របសម្រួល និងផ្តល់យោបល់ជូនក្រុមប្រឹក្សា **អ.ស.ហ.** លើទំនាស់នៃការអនុវត្តបទប្បញ្ញត្តិ រួមទាំងបញ្ហាឆ្លងវិស័យ
- សម្របសម្រួលការផ្តល់យោបល់ជូនក្រុមប្រឹក្សា **អ.ស.ហ.** លើបញ្ហាបច្ចេកទេស និងបញ្ហាប្រឈមនានា ពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ តាមការណែនាំរបស់ក្រុមប្រឹក្សា **អ.ស.ហ.**
- រៀបចំដាក់ឱ្យដំណើរការនិងគ្រប់គ្រងនូវប្រព័ន្ធប្រមូលព័ត៌មាន និងទិន្នន័យរបស់ **អ.ស.ហ.** រួមទាំងស្រាវជ្រាវ វិភាគ និងរៀបចំចងក្រងឯកសារ
- សម្របសម្រួល និងបូកសរុបសំណើថវិកាប្រចាំឆ្នាំរបស់ **អ.ស.ហ.** ជូនក្រុមប្រឹក្សា **អ.ស.ហ.** ពិនិត្យ និងសម្រេច រួមទាំងការរៀបចំថវិកាសម្រាប់កិច្ចដំណើរការនៃ **អ.ស.ហ.** អគ្គលេខាធិការដ្ឋាននិង អង្គភាពសវនកម្មនៃ **អ.ស.ហ.**
- សម្របសម្រួល និងតាមដានការអនុវត្តផែនការសកម្មភាពទាក់ទងនឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- សម្របសម្រួលជាមួយនិយ័តករពាក់ព័ន្ធ លើការបណ្តុះបណ្តាលនិងការកសាងសមត្ថភាពសម្រាប់មន្ត្រី **អ.ស.ហ.**
- រៀបចំផ្សព្វផ្សាយនិងលើកកម្ពស់ការយល់ដឹងសាធារណៈអំពីគោលនយោបាយនិងយុទ្ធសាស្ត្រអភិឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- គ្រប់គ្រងហិរញ្ញវត្ថុ និងបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន
- សម្របសម្រួលការគ្រប់គ្រងធនធានមនុស្ស និងការរៀបចំថវិកា របស់ **អ.ស.ហ.**
- គ្រប់គ្រងបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិរដ្ឋរបស់ **អ.ស.ហ.** និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលត្រូវបានបែងចែកឱ្យនៅក្រោមអគ្គលេខាធិការដ្ឋាន
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

មាត្រា ៤.-

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានមានតួនាទី និងភារកិច្ចដូចតទៅ÷

- ដឹកនាំការអនុវត្តន៍នូវតួនាទីនិងភារកិច្ចដូចមានចែងក្នុងមាត្រា៣ នៃអនុក្រឹត្យនេះ
- គ្រប់គ្រងការងារប្រចាំថ្ងៃរបស់អគ្គលេខាធិការដ្ឋាន
- រៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សា **អ.ស.ហ.**
- គ្រប់គ្រងចំណូល និងចំណាយរបស់អគ្គលេខាធិការដ្ឋាន
- ជាតំណាងឱ្យអគ្គលេខាធិការដ្ឋានក្នុងកិច្ចទំនាក់ទំនងជាមួយស្ថាប័នជាតិ-អន្តរជាតិ និងវិស័យឯកជន
- ចុះហត្ថលេខាលើកិច្ចសន្យា និងកិច្ចព្រមព្រៀងផ្សេងៗ ក្នុងនាមអគ្គលេខាធិការដ្ឋាន និង **អ.ស.ហ.** ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

មាត្រា ៥.-

អគ្គលេខាធិការដ្ឋានមាននាយកដ្ឋានចំណុះចំនួន ៤ (បួន) ដូចខាងក្រោម÷

- នាយកដ្ឋានកិច្ចការទូទៅ
- នាយកដ្ឋានគោលនយោបាយ
- នាយកដ្ឋានបច្ចេកទេស និងកិច្ចការគតិយុត្ត
- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ។

មាត្រា ៦.-

នាយកដ្ឋានកិច្ចការទូទៅជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋានលើតួនាទីនិងភារកិច្ចដូចខាងក្រោម÷

- សម្របសម្រួល និងបូកសរុបផែនការសកម្មភាពរួមរបស់អគ្គលេខាធិការដ្ឋាន
- រៀបចំ និងអនុវត្តផែនការសកម្មភាព របស់នាយកដ្ឋានកិច្ចការទូទៅ
- សម្របសម្រួល និងរៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សា **អ.ស.ហ.**
- សម្របសម្រួល និងបូកសរុបសំណើថវិកាប្រចាំឆ្នាំរបស់ **អ.ស.ហ.** ជូនក្រុមប្រឹក្សា **អ.ស.ហ.** ពិនិត្យ និងសម្រេច រួមទាំងការរៀបចំថវិកាសម្រាប់កិច្ចដំណើរការនៃ **អ.ស.ហ.** អគ្គលេខាធិការដ្ឋាន និងអង្គភាពសវនកម្មនៃ **អ.ស.ហ.**
- គ្រប់គ្រងកិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន
- សម្របសម្រួលការគ្រប់គ្រងធនធានមនុស្សរបស់ **អ.ស.ហ.**
- គ្រប់គ្រងបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិរដ្ឋរបស់ **អ.ស.ហ.** និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលត្រូវបានបែងចែកឱ្យនៅក្រោមអគ្គលេខាធិការដ្ឋាន

- រៀបចំ ដាក់ឱ្យដំណើរការ និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងនិងការផ្សព្វ-ផ្សាយរបស់ **អ.ស.ហ.**
- ទំនាក់ទំនងជាមួយស្ថាប័នជាតិ-អន្តរជាតិ និងវិស័យឯកជន
- ផ្សព្វផ្សាយជាសាធារណៈពីកិច្ចដំណើរការនិងវឌ្ឍនភាពរបស់ **អ.ស.ហ.**
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន។

មាត្រា ៧.-

នាយកដ្ឋានគោលនយោបាយ ជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋានលើតួនាទី និងភារកិច្ចដូចខាងក្រោម÷

- សម្របសម្រួល រៀបចំ និងអនុវត្តន្ធរគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមទាំងបច្ចេកវិទ្យាហិរញ្ញវត្ថុ
- រៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមទាំងតាមដាន និងវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្ត
- រៀបចំ និងអនុវត្តផែនការសកម្មភាពរបស់នាយកដ្ឋានគោលនយោបាយ
- សម្របសម្រួលការចែករំលែកព័ត៌មានរវាងនិយ័តករនៃ **អ.ស.ហ.**
- សម្របសម្រួលជាមួយនិយ័តករពាក់ព័ន្ធ ដើម្បីតាមដាន វិភាគ និងរៀបចំរបាយការណ៍ស្តីពីវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- តាមដាន វិភាគ និងផ្តល់យោបល់ អំពីហានិភ័យដែលមានលក្ខណៈជាប្រព័ន្ធ ឆ្លងវិស័យក្នុងវិស័យពាក់ព័ន្ធនឹងស្ថិរភាពហិរញ្ញវត្ថុ
- សម្របសម្រួលការអភិវឌ្ឍយន្តការគ្រប់គ្រងស្ថិរភាពនិងសំណាញ់សុវត្ថិភាពក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ប្រមូល និងចងក្រងទិន្នន័យនៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- ធ្វើការងារបណ្ណាសាររបស់ **អ.ស.ហ.**
- រៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល ការបោះពុម្ព និងការផ្សព្វផ្សាយព័ត៌មានានា ដើម្បីលើកកម្ពស់ការយល់ដឹងសាធារណៈអំពីប្រតិបត្តិការរបស់ **អ.ស.ហ.**
- រៀបចំ ចងក្រងឯកសារ និងធ្វើរបាយការណ៍ប្រចាំឆ្នាំរបស់ **អ.ស.ហ.**
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន។

មាត្រា ៨.-

នាយកដ្ឋានបច្ចេកទេស និងកិច្ចការគតិយុត្ត ជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន លើតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តផែនការសកម្មភាពរបស់នាយកដ្ឋានបច្ចេកទេស និងកិច្ចការគតិយុត្ត
- រៀបចំក្របខ័ណ្ឌរួម និងតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់ **អ.ស.ហ.**

- តាមដាន និងវាយតម្លៃការអនុវត្តផែនការសកម្មភាពទាក់ទងនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលស្ថិតក្រោមសមត្ថកិច្ច **អ.ស.ហ.**
- ពិនិត្យ និងផ្តល់យោបល់ទាំងទិដ្ឋភាពច្បាប់និងបច្ចេកទេស សម្រាប់ការស្នើសុំការអនុម័តបទប្បញ្ញត្តិ វិធាន និងនីតិវិធីពាក់ព័ន្ធនានា
- ពិនិត្យ និងផ្តល់យោបល់លើបញ្ហាបច្ចេកទេសនិងបញ្ហាប្រឈមនានា ពាក់ព័ន្ធនឹងការអនុវត្តមុខងាររបស់ **អ.ស.ហ.**
- ពិនិត្យ និងផ្តល់យោបល់លើទំនាស់នៃការអនុវត្តបទប្បញ្ញត្តិ រួមទាំងបញ្ហាឆ្លងវិស័យ
- ផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន។

មាត្រា ៩.-

មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ មានមុខងារ និងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តផែនការសកម្មភាពរបស់មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ
- សិក្សាឧត្តមានុវត្តអន្តរជាតិពាក់ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ
- រៀបចំ និងស្នើឡើងនូវផែនការមេសម្រាប់លើកស្ទួយ និងជំរុញការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ
- គាំទ្រ និងផ្តល់យោបល់ជូន **អ.ស.ហ.** លើការរៀបចំបទប្បញ្ញត្តិពាក់ព័ន្ធនឹងនវានុវត្តន៍ បច្ចេកវិទ្យាហិរញ្ញវត្ថុ និងនិន្នាការទីផ្សារ គំរូអាជីវកម្មថ្មី សេវាកម្ម ផលិតផល រួមទាំងហានិភ័យពាក់ព័ន្ធ
- ផ្សព្វផ្សាយបទប្បញ្ញត្តិថ្មីៗ ដែលទាក់ទងនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ
- សម្របសម្រួល និងគាំទ្រដល់និយ័តករក្នុងការផ្តល់អាជ្ញាបណ្ណ ការអនុញ្ញាត ឬការទទួលស្គាល់ក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុ
- គាំទ្រដល់និយ័តករក្នុងការដាក់ឱ្យដំណើរការសេនបុក្ស (Sandboxes) សម្រាប់បច្ចេកវិទ្យាហិរញ្ញវត្ថុ
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន។

ជំពូកទី៣
និយ័តករធានារ៉ាប់រងកម្ពុជា

មាត្រា ១០.-

និយ័តករធានារ៉ាប់រងកម្ពុជា (សរសេរកាត់ថា **ន.ធ.ក.**) បំពេញមុខងារជាសេនាធិការឱ្យ **អ.ស.ហ.**។ **ន.ធ.ក.** មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តនូវគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃវិស័យធានារ៉ាប់រង និងសោធនឯកជន
- ត្រួតពិនិត្យ និងតាមដានអនុលោមភាពនៃការអនុវត្តច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យធានារ៉ាប់រង និងសោធនឯកជន

- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃស្ថានភាពអាជីវកម្ម និងហិរញ្ញវត្ថុ ដើម្បីធានាភាពរឹងមាំរបស់គ្រឹះស្ថានធានារ៉ាប់រងនិងសោធនឯកជន
- រៀបចំ ធ្វើបច្ចុប្បន្នភាព និងស្នើសុំការអនុម័តន្ធវបទប្បញ្ញត្តិពាក់ព័ន្ធសម្រាប់គ្រប់គ្រងវិស័យធានារ៉ាប់រងនិងសោធនឯកជន
- លើកកម្ពស់ការអប់រំ បណ្តុះបណ្តាល និងផ្សព្វផ្សាយដល់សាធារណជន
- ចូលរួមក្នុងកិច្ចសហប្រតិបត្តិការតំបន់និងអន្តរជាតិ
- គ្រប់គ្រងមូលនិធិអភិវឌ្ឍន៍វិស័យធានារ៉ាប់រង តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**
- គ្រប់គ្រងហិរញ្ញវត្ថុ និងបុគ្គលិករបស់ **ន.ធ.ក.**
- សម្របសម្រួលការគ្រប់គ្រងធនធានមនុស្ស និងការរៀបចំថវិការបស់ **ន.ធ.ក** ជាមួយអគ្គលេខាធិការដ្ឋាន
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលត្រូវបានបែងចែកឱ្យនៅក្រោម **ន.ធ.ក.** និងរៀបចំបញ្ជីសារពើភ័ណ្ឌ ជូនអគ្គលេខាធិការដ្ឋាន
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

មាត្រា ១១.-

អគ្គនាយកនៃ **ន.ធ.ក.** មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- ដឹកនាំការអនុវត្តន្ធវត្តនាទី និងភារកិច្ចដូចមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះ
- គ្រប់គ្រងការងារប្រចាំថ្ងៃរបស់ **ន.ធ.ក.**
- រៀបចំ ស្នើឡើង និងអនុវត្តថវិកាប្រចាំឆ្នាំ រួមទាំងការគ្រប់គ្រងចំណូល និងចំណាយសម្រាប់កិច្ចដំណើរការ **ន.ធ.ក.**
- ពិនិត្យពាក្យស្នើសុំអាជ្ញាបណ្ណ វិញ្ញាបនបត្រ ការអនុញ្ញាត ឬការចុះបញ្ជី និងផ្តល់ ឬមិនផ្តល់អាជ្ញាបណ្ណ វិញ្ញាបនបត្រ ការអនុញ្ញាត ឬការចុះបញ្ជី នៅពេលដែលអ្នកស្នើសុំបានបំពេញ ឬមិនបានបំពេញតាមលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធវិស័យធានារ៉ាប់រងនិងសោធនឯកជន និងលក្ខខណ្ឌផ្សេងទៀតដែលក្រុមប្រឹក្សា **អ.ស.ហ.** បានកំណត់
- ចាត់វិធានការសមស្របដែលច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធវិស័យធានារ៉ាប់រងនិងសោធនឯកជនអនុញ្ញាត ចំពោះអំពើល្មើសទៅនឹងលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធវិស័យធានារ៉ាប់រងនិងសោធនឯកជន
- ជាតំណាងឱ្យ **ន.ធ.ក.** នៅចំពោះមុខតុលាការ ចុះកិច្ចសន្យា និងកិច្ចព្រមព្រៀងផ្សេងៗក្នុងនាម **ន.ធ.ក.** ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**
- ជាតំណាងឱ្យ **ន.ធ.ក.** ក្នុងកិច្ចទំនាក់ទំនងជាមួយស្ថាប័នជាតិ-អន្តរជាតិ និងវិស័យឯកជន

- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

មាត្រា ១២.-

ន.ធ.ក. មាននាយកដ្ឋានចំណុះចំនួន ៥ (ប្រាំ) ដូចខាងក្រោម÷

- នាយកដ្ឋានកិច្ចការទូទៅ
- នាយកដ្ឋានគ្រប់គ្រងអាជ្ញាបណ្ណ និងកិច្ចការគតិយុត្ត
- នាយកដ្ឋានត្រួតពិនិត្យ
- នាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ
- នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ។

មាត្រា ១៣.-

នាយកដ្ឋានកិច្ចការទូទៅជាសេនាធិការឱ្យ **ន.ធ.ក.** លើតួនាទី និងភារកិច្ចដូចខាងក្រោម÷

- សម្របសម្រួល និងបូកសរុបផែនការសកម្មភាពរួមរបស់ **ន.ធ.ក.**
- រៀបចំ និងអនុវត្តផែនការសកម្មភាពរបស់នាយកដ្ឋានកិច្ចការទូទៅ
- រៀបចំថវិកាសម្រាប់កិច្ចដំណើរការរបស់ **ន.ធ.ក.**
- គ្រប់គ្រងកិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិករបស់ **ន.ធ.ក.**
- សម្របសម្រួលការគ្រប់គ្រងធនធានមនុស្សរបស់ **ន.ធ.ក.**
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលត្រូវបានបែងចែកឱ្យនៅក្រោម **ន.ធ.ក.** និងរៀបចំបញ្ជីសារពើភ័ណ្ឌ
- រៀបចំ ដាក់ឱ្យដំណើរការ និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រង និងការផ្សព្វផ្សាយរបស់ **ន.ធ.ក.**
- ទំនាក់ទំនងជាមួយស្ថាប័នជាតិ-អន្តរជាតិ និងវិស័យឯកជន
- ផ្សព្វផ្សាយជាសាធារណៈពីកិច្ចដំណើរការនិងវឌ្ឍនភាពរបស់ **ន.ធ.ក.**
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គនាយកនៃ **ន.ធ.ក.**។

មាត្រា ១៤.-

នាយកដ្ឋានគ្រប់គ្រងអាជ្ញាបណ្ណ និងកិច្ចការគតិយុត្ត ជាសេនាធិការឱ្យ **ន.ធ.ក.** លើតួនាទីនិងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តផែនការសកម្មភាពរបស់នាយកដ្ឋានគ្រប់គ្រងអាជ្ញាបណ្ណ និងកិច្ចការគតិយុត្ត
- ពិនិត្យ និងផ្តល់យោបល់លើសំណើសុំអាជ្ញាបណ្ណ វិញ្ញាបនបត្រ ការអនុញ្ញាត ឬការចុះបញ្ជីអាជីវកម្មធានារ៉ាប់រងនិងសោធនឯកជន និងអាជីវកម្មគាំទ្រ
- ពិនិត្យ និងផ្តល់យោបល់លើសំណើសុំការអនុញ្ញាតផ្លាស់ប្តូរនាមករណ៍ និមិត្តសញ្ញា អាសយដ្ឋាន ឬសមាជិកភាគហ៊ុន របស់គ្រឹះស្ថានធានារ៉ាប់រងនិងសោធនឯកជន និងការអនុញ្ញាតផ្សេងទៀត

- ពិនិត្យ និងផ្តល់យោបល់លើវិធានការចំពោះអំពើល្មើសទាំងឡាយណា ដែលទាក់ទងនឹងការអនុវត្តបទប្បញ្ញត្តិស្តីពីការផ្តល់អាជ្ញាបណ្ណ វិញ្ញាបនបត្រ ការអនុញ្ញាត និងការចុះបញ្ជីអាជីវកម្មធានារ៉ាប់រងនិងសោធនឯកជន និងអាជីវកម្មគាំទ្រ
- រៀបចំ និងធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិចាំបាច់នានាទាក់ទងនឹងការផ្តល់អាជ្ញាបណ្ណ វិញ្ញាបនបត្រ ការអនុញ្ញាត ឬការចុះបញ្ជីអាជីវកម្មធានារ៉ាប់រងនិងសោធនឯកជន និងអាជីវកម្មគាំទ្រ
- ពិនិត្យ និងផ្តល់យោបល់លើទម្រង់ និងខ្លឹមសារនៃបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យធានារ៉ាប់រងនិងសោធនឯកជនរបស់ **ន.ធ.ក.**
- រៀបចំនីតិវិធី និងដោះស្រាយពាក្យបណ្តឹងធានារ៉ាប់រងនិងសោធនឯកជន
- រៀបចំ និងគ្រប់គ្រងទិន្នន័យអំពីគ្រឹះស្ថានធានារ៉ាប់រងនិងសោធនឯកជន
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គនាយកនៃ **ន.ធ.ក.**។

មាត្រា ១៥.-

នាយកដ្ឋានត្រួតពិនិត្យ ជាសេនាធិការឱ្យ **ន.ធ.ក.** លើតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តផែនការសកម្មភាពការងាររបស់នាយកដ្ឋានត្រួតពិនិត្យ
- ត្រួតពិនិត្យលើឯកសារ និងតាមដានស្ថានភាពហានិភ័យហិរញ្ញវត្ថុប្រចាំគ្រារបស់គ្រឹះស្ថានធានារ៉ាប់រងនិងសោធនឯកជន
- ត្រួតពិនិត្យដល់ទីកន្លែងជាប្រចាំ ឬតាមការចាំបាច់ ចំពោះគ្រឹះស្ថានធានារ៉ាប់រងនិងសោធនឯកជន ដើម្បីវាយតម្លៃស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានធានារ៉ាប់រងនិងសោធនឯកជន និងអនុលោមភាពនៃច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ
- ផ្តល់យោបល់លើវិធានការចំពោះអំពើល្មើសទៅនឹងបទប្បញ្ញត្តិ ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានធានារ៉ាប់រងនិងសោធនឯកជន
- រៀបចំ និងធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្តិ ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានធានារ៉ាប់រងនិងសោធនឯកជន
- ពិនិត្យ និងផ្តល់យោបល់លើការស្នើសុំតែងតាំង ឬផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល ឬគណៈគ្រប់គ្រង សមាសភាពគណៈកម្មការសវនកម្ម សវនករឯករាជ្យ ឬអ្នកជំនាញគណនាហានិភ័យធានារ៉ាប់រង ឬការអនុញ្ញាតឱ្យបង្កើន ឬបន្ថយដើមទុនចុះបញ្ជីរបស់គ្រឹះស្ថានធានារ៉ាប់រងនិងសោធនឯកជន និងការអនុញ្ញាតផ្សេងទៀត
- ពិនិត្យ និងផ្តល់យោបល់លើសំណើសុំគោលការណ៍អនុញ្ញាតប្រកបអាជីវកម្មជាគ្រឹះស្ថានធានារ៉ាប់រងនិងសោធនឯកជន និងអាជីវកម្មគាំទ្រផ្សេងទៀត និងលើសំណើសុំចុះបញ្ជីក្រុមហ៊ុនសវនកម្ម និងអ្នកជម្រះបញ្ជីក្រុមហ៊ុនធានារ៉ាប់រងនិងសោធនឯកជន និងអាជីវកម្មគាំទ្រ
- ពិនិត្យ និងគ្រប់គ្រងលើដំណើរការជម្រះបញ្ជីគ្រឹះស្ថានធានារ៉ាប់រងនិងសោធនឯកជន
- រៀបចំ និងគ្រប់គ្រងទិន្នន័យហិរញ្ញវត្ថុនៃទីផ្សារធានារ៉ាប់រងនិងសោធនឯកជន
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គនាយកនៃ **ន.ធ.ក.**។

មាត្រា ១៦.-

នាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ ជាសេនាធិការឱ្យ **ន.ធ.ក.** លើតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តផែនការសកម្មភាពរបស់នាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ
- ពិនិត្យ និងផ្តល់យោបល់លើការសុំលក់ កែប្រែ និងផ្សព្វផ្សាយផលិតផលធានារ៉ាប់រងនិងសោធនឯកជន រួមទាំងការសុំលក់ កែប្រែ និងផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិករបស់គ្រឹះស្ថានធានារ៉ាប់រងនិងសោធនឯកជន
- តាមដាន និងត្រួតពិនិត្យដល់ទីកន្លែងលើការអនុវត្តក្រមប្រតិបត្តិនៃទីផ្សារធានារ៉ាប់រងនិងសោធនឯកជនរបស់គ្រឹះស្ថានធានារ៉ាប់រងនិងសោធនឯកជន
- ផ្តល់យោបល់លើវិធានការចំពោះអំពើល្មើសទៅនឹងក្រមប្រតិបត្តិនៃទីផ្សារធានារ៉ាប់រងនិងសោធនឯកជន
- សិក្សា និងតាមដានការវិវត្តនៃប្រភេទផលិតផលនិងការលក់ផលិតផលធានារ៉ាប់រងនិងសោធនឯកជន រួមទាំងការលក់តាមប្រព័ន្ធអេឡិចត្រូនិកនៅលើទីផ្សារក្នុងតំបន់ និងពិភពលោក
- រៀបចំ និងធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិទាក់ទងនឹងក្រមប្រតិបត្តិទីផ្សារ ការធ្វើអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការការពារអ្នកប្រើប្រាស់នៅក្នុងវិស័យធានារ៉ាប់រងនិងសោធនឯកជន
- រៀបចំ និងគ្រប់គ្រងទិន្នន័យអំពីផលិតផលក្នុងទីផ្សារធានារ៉ាប់រងនិងសោធនឯកជន
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គនាយកនៃ **ន.ធ.ក.**។

មាត្រា ១៧.-

នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ ជាសេនាធិការឱ្យ **ន.ធ.ក.** លើតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តផែនការសកម្មភាពរបស់នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ
- សិក្សា ស្រាវជ្រាវ និងរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងនិងសោធនឯកជន
- រៀបចំការបណ្តុះបណ្តាល និងការផ្សព្វផ្សាយ ដើម្បីបង្កើនការយល់ដឹងរបស់សាធារណជន
- សហការជាមួយនិយ័តករធានារ៉ាប់រងនិងសោធនឯកជននៃបណ្តាប្រទេសផ្សេងទៀត និងដៃគូពាក់ព័ន្ធជាតិ និងអន្តរជាតិ
- រៀបចំស្ថិយវាយតម្លៃប្រចាំត្រានិងប្រចាំឆ្នាំ លើអនុលោមភាពទៅនឹងគោលការណ៍គ្រឹះធានារ៉ាប់រងនៃសមាគមនិយ័តករធានារ៉ាប់រងអន្តរជាតិ
- ចូលរួមអនុវត្តផែនការសកម្មភាពទាក់ទងនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ការពង្រឹងស្ថិរភាពហិរញ្ញវត្ថុ និងការជំរុញបរិយាប័ន្នហិរញ្ញវត្ថុ
- រៀបចំ អភិវឌ្ឍ និងគ្រប់គ្រងបច្ចេកវិទ្យាធានារ៉ាប់រងរបស់ **ន.ធ.ក.**
- រៀបចំ និងផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំអំពីវិស័យធានារ៉ាប់រងនិងសោធនឯកជន
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គនាយកនៃ **ន.ធ.ក.**។

ជំពូកទី៤
និយ័តករមូលបត្រកម្ពុជា

មាត្រា ១៨.-

ការរៀបចំនិងការប្រព្រឹត្តទៅនៃនិយ័តករមូលបត្រកម្ពុជា (ហៅកាត់ថា **ន.ម.ក.**) ត្រូវអនុវត្តតាមអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា។ គណៈកម្មការមូលបត្រកម្ពុជាត្រូវបានប្រែក្លាយទៅជានិយ័តករមូលបត្រកម្ពុជា ដើម្បីបំពេញមុខងារជាសេនាធិការឱ្យ **អ.ស.ហ.** ស្របតាមច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

មាត្រា ១៩.-

ត្រូវបានលុបចេញនូវអង្គភាពសវនកម្មផ្ទៃក្នុងដូចដែលមានកំណត់ក្នុងអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា ពីរចនាសម្ព័ន្ធរបស់និយ័តករមូលបត្រកម្ពុជា។

មាត្រា ២០.-

និយ័តករមូលបត្រកម្ពុជាត្រូវអនុវត្តតាមបញ្ញត្តិនៃអនុក្រឹត្យលេខ ១០៧ អនក្រ.បក ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១ ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់របស់មន្ត្រី ភ្នាក់ងារនគរបាលយុត្តិធម៌ នៃគណៈកម្មការមូលបត្រកម្ពុជា និងប្រើប្រាស់និមិត្តសញ្ញារបស់គណៈកម្មការមូលបត្រកម្ពុជា ដោយកែសម្រួលត្រង់ផ្នែកព័ទ្ធជារង្វង់នៅផ្នែកខាងលើដោយអក្សរខ្មែរថា "គណៈកម្មការមូលបត្រកម្ពុជា" ដែលប្តូរទៅជា "និយ័តករមូលបត្រកម្ពុជា" និងផ្នែកព័ទ្ធជារង្វង់នៅផ្នែកខាងក្រោមដោយអក្សរអង់គ្លេសថា "SECURITIES AND EXCHANGE COMMISSION OF CAMBODIA" ដែលប្តូរទៅជា "SECURITIES AND EXCHANGE REGULATOR OF CAMBODIA" ។

ជំពូកទី៥
និយ័តករសន្តិសុខសង្គម

មាត្រា ២១.-

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម បំពេញមុខងារបន្ថែមជានិយ័តករសន្តិសុខសង្គម (ហៅកាត់ថា **ន.ស.ស.**) ដែលជាសេនាធិការឱ្យ **អ.ស.ហ.** ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ **ន.ស.ស.** មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពសម្រាប់អនុវត្តតួនាទី និងភារកិច្ចដូចមានចែងក្នុងមាត្រា១១ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម
- ត្រួតពិនិត្យ និងតាមដានអនុលោមភាពនៃការអនុវត្តច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងប្រព័ន្ធសន្តិសុខសង្គម
- ត្រួតពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តរបស់ប្រតិបត្តិករសន្តិសុខសង្គម និងតួអង្គពាក់ព័ន្ធ

- រៀបចំ ធ្វើបច្ចុប្បន្នភាព និងស្នើសុំការអនុម័តនូវបទប្បញ្ញត្តិពាក់ព័ន្ធសម្រាប់គ្រប់គ្រងប្រតិបត្តិការសន្តិសុខសង្គមនិងតួអង្គពាក់ព័ន្ធ
- លើកកម្ពស់ការអប់រំ បណ្តុះបណ្តាល និងផ្សព្វផ្សាយដល់សាធារណជន
- ចូលរួមក្នុងកិច្ចសហប្រតិបត្តិការតំបន់និងអន្តរជាតិ
- គ្រប់គ្រងហិរញ្ញវត្ថុ និងបុគ្គលិករបស់ **ន.ស.ស.**
- សម្របសម្រួលការគ្រប់គ្រងធនធានមនុស្សជាមួយអគ្គលេខាធិការដ្ឋាន
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលត្រូវបានបែងចែកឱ្យនៅក្រោម **ន.ស.ស.** និងរៀបចំបញ្ជីសារពើភ័ណ្ឌជូនអគ្គលេខាធិការដ្ឋាន
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

មាត្រា ២២.-

អគ្គនាយកនៃ **ន.ស.ស.** មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- ដឹកនាំការអនុវត្តនូវតួនាទី និងភារកិច្ចដូចមានចែងក្នុងមាត្រា ២១ នៃអនុក្រឹត្យនេះ
- គ្រប់គ្រងការងារប្រចាំថ្ងៃរបស់ **ន.ស.ស.**
- ចាត់វិធានការសមស្របដែលច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធអនុញ្ញាត ចំពោះអំពើល្មើសនីតិលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ
- ជាតំណាងឱ្យ **ន.ស.ស.** នៅចំពោះមុខតុលាការ ចុះកិច្ចសន្យា និងកិច្ចព្រមព្រៀងផ្សេងៗក្នុងនាម **ន.ស.ស.** ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**
- ជាតំណាងឱ្យ **ន.ស.ស.** ក្នុងកិច្ចទំនាក់ទំនងជាមួយស្ថាប័នជាតិ-អន្តរជាតិ និងវិស័យឯកជន
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

មាត្រា ២៣.-

និយ័តករសន្តិសុខសង្គមប្រើរចនាសម្ព័ន្ធកម្រិតនាយកដ្ឋាន ដូចមានកំណត់ក្នុងអនុក្រឹត្យស្តីពី "ការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម" សម្រាប់ការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន។

ជំពូកទី៦

និយ័តករបរធនបាលកិច្ច

មាត្រា ២៤.-

និយ័តករបរធនបាលកិច្ច (សរសេរកាត់ថា **ន.ប.ធ.**) បំពេញមុខងារជាសេនាធិការឱ្យ **អ.ស.ហ.**។ **ន.ប.ធ.** មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តនូវគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃវិស័យបរធន-បាលកិច្ច
- ត្រួតពិនិត្យ និងតាមដានអនុលោមភាពនៃការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច
- រៀបចំ ធ្វើបច្ចុប្បន្នភាព និងស្នើសុំការអនុម័តនូវបទប្បញ្ញត្តិពាក់ព័ន្ធសម្រាប់ការចុះបញ្ជីបរធន-បាលកិច្ច ការផ្តល់ការអនុញ្ញាត និង/ឬការចុះបញ្ជីប្រតិបត្តិករជាបរធនបាល និងអ្នកចូលរួមដទៃទៀតក្នុងវិស័យបរធនបាលកិច្ច
- រៀបចំ ធ្វើបច្ចុប្បន្នភាព និងស្នើសុំការអនុម័តនូវបទប្បញ្ញត្តិពាក់ព័ន្ធនឹងការចុះបញ្ជីបរធនបាលដែលទទួលបានអាជ្ញាបណ្ណពីនិយ័តករមូលបត្រកម្ពុជា រួមទាំងការកំណត់នូវការបែងចែករវាងបរធននិងបរធនវិនិយោគនៃគម្រោងវិនិយោគរួម ដែលស្ថិតក្រោមនិយ័តកម្មនៃវិស័យមូលបត្រ
- រៀបចំ ធ្វើបច្ចុប្បន្នភាព និងស្នើសុំការអនុម័តនូវបទប្បញ្ញត្តិពាក់ព័ន្ធនឹងការអនុញ្ញាត និង/ឬការចុះបញ្ជីរបវន្តបុគ្គល/នីតិបុគ្គល ដែលធ្វើប្រតិបត្តិការបរធនបាលកិច្ច
- ពិនិត្យ និងស្នើសុំរៀបចំក្រុមប្រឹក្សាដោះស្រាយវិវាទពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ច
- លើកកម្ពស់ការអប់រំ បណ្តុះបណ្តាល និងផ្សព្វផ្សាយដល់សាធារណជន
- ចូលរួមក្នុងកិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិ
- គ្រប់គ្រងមូលនិធិទ្រទ្រង់ និងអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**
- គ្រប់គ្រងហិរញ្ញវត្ថុ និងបុគ្គលិករបស់ **ន.ប.ធ.**
- សម្របសម្រួលការគ្រប់គ្រងធនធានមនុស្ស និងរៀបចំថវិការបស់ **ន.ប.ធ.** ជាមួយអគ្គលេខាធិការដ្ឋាន
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលត្រូវបានបែងចែកឱ្យនៅក្រោម **ន.ប.ធ.** និងរៀបចំបញ្ជីសារពើភ័ណ្ឌ ជូនអគ្គលេខាធិការដ្ឋាន
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** ។

មាត្រា ២៥.-

អគ្គនាយកនៃ **ន.ប.ធ.** មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- ដឹកនាំការអនុវត្តនូវតួនាទី និងភារកិច្ចដូចមានចែងក្នុងមាត្រា២៤ នៃអនុក្រឹត្យនេះ
- គ្រប់គ្រងការងារប្រចាំថ្ងៃរបស់ **ន.ប.ធ.**
- រៀបចំ ស្នើឡើង និងអនុវត្តថវិកាប្រចាំឆ្នាំ រួមទាំងការគ្រប់គ្រងចំណូល និងចំណាយសម្រាប់កិច្ចដំណើរការ **ន.ប.ធ.**

- ពិនិត្យពាក្យស្នើសុំការចុះបញ្ជីបរធនបាលកិច្ច ការអនុញ្ញាត និង/ឬការចុះបញ្ជីប្រតិបត្តិករជាបរធនបាល រូបវន្តបុគ្គល/នីតិបុគ្គលដែលធ្វើប្រតិបត្តិការបរធនបាលកិច្ច និងអ្នកចូលរួមដទៃទៀតក្នុងវិស័យបរធនបាលកិច្ច និងផ្តល់ ឬមិនផ្តល់វិញ្ញាបនបត្រចុះបញ្ជី ផ្តល់ ឬមិនផ្តល់ការអនុញ្ញាតនិង/ឬការចុះបញ្ជី នៅពេលអ្នកស្នើសុំបំពេញ ឬមិនបានបំពេញតាមលក្ខខណ្ឌនៃច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធវិស័យបរធនបាលកិច្ច និងលក្ខខណ្ឌផ្សេងទៀតដែលក្រុមប្រឹក្សាបានកំណត់
- ចាត់វិធានការសមស្របដែលច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធវិស័យបរធនបាលកិច្ចអនុញ្ញាតចំពោះអំពើល្មើសនឹងលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធវិស័យបរធនបាលកិច្ច។
- ជាតំណាងឱ្យ **ន.ប.ឆ.** នៅចំពោះមុខតុលាការ ចុះកិច្ចសន្យា និងកិច្ចព្រមព្រៀងផ្សេងៗក្នុងនាម **ន.ប.ឆ.** ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**
- ជាតំណាងឱ្យ **ន.ប.ឆ.** ក្នុងកិច្ចទំនាក់ទំនងជាមួយស្ថាប័នជាតិ-អន្តរជាតិ និងវិស័យឯកជន
- អនុវត្តការងារផ្សេងៗទៀត តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

មាត្រា ២៦.-

ន.ប.ឆ. មាននាយកដ្ឋានចំណុះចំនួន ៤ (បួន) ដូចខាងក្រោម÷

- នាយកដ្ឋានកិច្ចការទូទៅ
- នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច
- នាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច
- នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ។

មាត្រា ២៧.-

នាយកដ្ឋានកិច្ចការទូទៅ ជាសេនាធិការឱ្យ **ន.ប.ឆ.** លើតួនាទី និងភារកិច្ចដូចខាងក្រោម÷

- សម្របសម្រួល និងបូកសរុបផែនការសកម្មភាពរួមរបស់ **ន.ប.ឆ.**
- រៀបចំ និងអនុវត្តផែនការសកម្មភាពរបស់នាយកដ្ឋានកិច្ចការទូទៅ
- រៀបចំថវិកាសម្រាប់កិច្ចដំណើរការរបស់ **ន.ប.ឆ.**
- គ្រប់គ្រងកិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិករបស់ **ន.ប.ឆ.**
- សម្របសម្រួលការគ្រប់គ្រងធនធានមនុស្សរបស់ **ន.ប.ឆ.**
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលត្រូវបានបែងចែកឱ្យនៅក្រោម **ន.ប.ឆ.** និងរៀបចំបញ្ជីសារពើភ័ណ្ឌ
- រៀបចំ ដាក់ឱ្យដំណើរការ និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងនិងការផ្សព្វផ្សាយរបស់ **ន.ប.ឆ.**
- ធ្វើកិច្ចទំនាក់ទំនងជាមួយស្ថាប័នជាតិ-អន្តរជាតិ និងវិស័យឯកជន

- ផ្សព្វផ្សាយជាសាធារណៈអំពីដំណើរការ និងវឌ្ឍនភាពរបស់ **ន.ប.ឆ.**
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គនាយក នៃ **ន.ប.ឆ.**។

មាត្រា ២៨.-

នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច ជាសេនាធិការឱ្យ**ន.ប.ឆ.** លើតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តផែនការសកម្មភាពការងាររបស់នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច
- រៀបចំ និងធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិឬលក្ខខណ្ឌតម្រូវនានា សម្រាប់ផ្តល់ការអនុញ្ញាតចុះបញ្ជីបរធនបាលកិច្ច ការអនុញ្ញាត និង/ឬការចុះបញ្ជីប្រតិបត្តិករជាបរធនបាល រូបវន្តបុគ្គល/នីតិបុគ្គលដែលធ្វើប្រតិបត្តិការបរធនបាលកិច្ច និងអ្នកចូលរួមដទៃទៀត
- ពិនិត្យ និងផ្តល់យោបល់លើការសុំចុះបញ្ជីបរធនបាលកិច្ចនិងការសុំការអនុញ្ញាត និង/ឬការចុះបញ្ជីប្រតិបត្តិករបរធនបាល រូបវន្តបុគ្គល/នីតិបុគ្គល ដែលធ្វើប្រតិបត្តិការបរធនបាលកិច្ច និងអ្នកចូលរួមដទៃទៀត
- ពិនិត្យ និងផ្តល់យោបល់លើការសុំផ្លាស់ប្តូរឬកែប្រែអាសយដ្ឋាន សមាសភាពក្រុមប្រឹក្សាភិបាល បរធនបាល ការបញ្ចប់បរធនបាលកិច្ច ឬការជម្រះបញ្ជីបរធនបាលកិច្ច
- ត្រួតពិនិត្យ និងតាមដានការអនុវត្តតាមលក្ខខណ្ឌនៃការចុះបញ្ជីបរធនបាលកិច្ច ប្រតិបត្តិការរបស់ប្រតិបត្តិករបរធនបាល រូបវន្តបុគ្គល/នីតិបុគ្គលដែលធ្វើប្រតិបត្តិការបរធនបាលកិច្ច និងអ្នកចូលរួមដទៃទៀត
- ត្រួតពិនិត្យដល់ទីកន្លែងនូវប្រតិបត្តិការបរធនបាលកិច្ច ប្រតិបត្តិការរបស់ប្រតិបត្តិករបរធនបាល រូបវន្តបុគ្គល/នីតិបុគ្គលដែលធ្វើប្រតិបត្តិការបរធនបាលកិច្ច និងអ្នកចូលរួមដទៃទៀត
- ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ របាយការណ៍អាជីវកម្ម ប្រតិវេទន៍ និងឯកសារចាំបាច់របស់បរធនបាលកិច្ច
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គនាយក នៃ **ន.ប.ឆ.**។

មាត្រា ២៩.-

នាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច ជាសេនាធិការឱ្យ **ន.ប.ឆ.** លើតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តផែនការសកម្មភាពការងាររបស់នាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច
- រៀបចំ និងធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិចាំបាច់នានា
- ពិនិត្យ និងផ្តល់យោបល់លើទម្រង់និងខ្លឹមសារនៃបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច
- តាមដាន ស្រាវជ្រាវ ធ្វើអធិការកិច្ច និងពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិ
- រៀបចំនីតិវិធីនិងដោះស្រាយពាក្យបណ្តឹងបរធនបាលកិច្ច
- ពិនិត្យ និងផ្តល់យោបល់លើវិធានការពិន័យពាក់ព័ន្ធនឹងអំពើល្មើសទៅនឹងបទប្បញ្ញត្តិ

- ចូលរួមអនុវត្តផែនការសកម្មភាពទាក់ទងនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ការពង្រឹងស្ថិរភាពហិរញ្ញវត្ថុ និងការជំរុញបរិយាប័ន្នហិរញ្ញវត្ថុ
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គនាយកនៃ **ន.ប.ធ.**។

មាត្រា ៣០.-

នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ ជាសេនាធិការឱ្យ **ន.ប.ធ.** លើតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តផែនការសកម្មភាពការងាររបស់នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ
- សិក្សាស្រាវជ្រាវលើការអភិវឌ្ឍវិស័យបរធនបាលកិច្ច
- សិក្សា វាយតម្លៃ និងផ្តល់យោបល់លើនវានុវត្តន៍បរធនបាលកិច្ច
- ចូលរួមអនុវត្តគម្រោងជាមួយដៃគូអភិវឌ្ឍន៍និងមូលនិធិផ្សេងៗ
- សហការជាមួយនិយ័តករបរធនបាលកិច្ចនៃបណ្តាប្រទេសផ្សេងទៀត និងដៃគូអភិវឌ្ឍន៍ជាតិ-អន្តរជាតិ
- រៀបចំការបណ្តុះបណ្តាលនិងការផ្សព្វផ្សាយដល់សាធារណជន និងអ្នកចូលរួមក្នុងវិស័យបរ-ធនបាលកិច្ច
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គនាយក នៃ **ន.ប.ធ.**។

ជំពូកទី៧
និយ័តករគណនេយ្យនិងសវនកម្ម

មាត្រា ៣១.-

និយ័តករគណនេយ្យនិងសវនកម្ម (សរសេរកាត់ថា **ន.គ.ស.**) បំពេញមុខងារជាសេនាធិការឱ្យ **អ.ស.ហ.**។ **ន.គ.ស.** មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តនូវគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃវិស័យគណនេយ្យ និងសវនកម្ម
- រៀបចំ ធ្វើបច្ចុប្បន្នភាព និងស្នើសុំការអនុម័តនូវបទប្បញ្ញត្តិពាក់ព័ន្ធសម្រាប់គ្រប់គ្រងវិស័យគណនេយ្យនិងសវនកម្ម
- រៀបចំ និងស្នើឡើងនូវស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម និងវិធាននិងនីតិវិធីអនុវត្តស្តង់ដាគណនេយ្យនិងសវនកម្ម
- ត្រួតពិនិត្យនិងតាមដានអនុលោមភាពនៃការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យគណនេយ្យនិងសវនកម្ម
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃស្ថានភាពនៃវិស័យគណនេយ្យនិងសវនកម្ម
- រៀបចំ ស្នើដាក់ឱ្យអនុវត្ត និងគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា
- លើកកម្ពស់ការអប់រំ បណ្តុះបណ្តាល និងផ្សព្វផ្សាយដល់សាធារណជន

- ចូលរួមក្នុងកិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិ
- គ្រប់គ្រងហិរញ្ញវត្ថុ និងបុគ្គលិករបស់ **ន.ត.ស.**
- សម្របសម្រួលការគ្រប់គ្រងធនធានមនុស្ស និងការរៀបចំថវិការបស់ **ន.ត.ស.** ជាមួយអគ្គលេខាធិការដ្ឋាន
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលត្រូវបានបែងចែកឱ្យនៅក្រោម **ន.ត.ស.** និងរៀបចំបញ្ជីសារពើភ័ណ្ឌជូនអគ្គលេខាធិការដ្ឋាន
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

មាត្រា ៣២.-

អគ្គនាយកនៃ **ន.ត.ស.** មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- ដឹកនាំការអនុវត្តនូវតួនាទី និងភារកិច្ចដូចមានចែងក្នុងមាត្រា ៣១ នៃអនុក្រឹត្យនេះ
- គ្រប់គ្រងការងារប្រចាំថ្ងៃរបស់ **ន.ត.ស.**
- រៀបចំ ស្នើឡើង និងអនុវត្តថវិកាប្រចាំឆ្នាំ រួមទាំងគ្រប់គ្រងចំណូល និងចំណាយសម្រាប់កិច្ច-ដំណើរការ **ន.ត.ស.**
- ពិនិត្យពាក្យស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិង/ឬអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម ឬការអនុញ្ញាតនានាក្នុងវិស័យគណនេយ្យនិងសវនកម្ម និងផ្តល់ឬមិនផ្តល់អាជ្ញាបណ្ណនិង/ឬការអនុញ្ញាតទាំងនោះ នៅពេលអ្នកស្នើសុំបានបំពេញ ឬមិនបានបំពេញលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធវិស័យគណនេយ្យនិងសវនកម្ម និងលក្ខខណ្ឌផ្សេងទៀតដែលក្រុមប្រឹក្សា **អ.ស.ហ.** បានកំណត់
- ចាត់វិធានការសមស្របដែលច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យគណនេយ្យនិងសវនកម្ម អនុញ្ញាត ចំពោះអំពើល្មើសនឹងលក្ខខណ្ឌនៃច្បាប់និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងគណនេយ្យនិងសវនកម្ម
- ជាតំណាងឱ្យ **ន.ត.ស.** នៅចំពោះមុខតុលាការ ចុះកិច្ចសន្យា និងកិច្ចព្រមព្រៀងផ្សេងៗក្នុងនាម **ន.ត.ស.** ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**
- ជាតំណាងឱ្យ **ន.ត.ស.** ក្នុងកិច្ចទំនាក់ទំនងជាមួយស្ថាប័នជាតិ-អន្តរជាតិ និងវិស័យឯកជន
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

មាត្រា ៣៣.-

ន.ត.ស. មាននាយកដ្ឋានចំណុះចំនួន ៤ (បួន) ដូចខាងក្រោម÷

- នាយកដ្ឋានកិច្ចការទូទៅ
- នាយកដ្ឋានបច្ចេកទេស

- នាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
- នាយកដ្ឋានកិច្ចការគតិយុត្ត និងអនុលោមភាព។

មាត្រា ៣៤.-

នាយកដ្ឋានកិច្ចការទូទៅ ជាសេនាធិការឱ្យ **ន.គ.ស.** លើតួនាទី និងភារកិច្ចដូចខាងក្រោម÷

- សម្របសម្រួល និងបូកសរុបផែនការសកម្មភាពរួម របស់ **ន.គ.ស.**
- រៀបចំ និងអនុវត្តផែនការសកម្មភាពការងាររបស់នាយកដ្ឋានកិច្ចការទូទៅ
- រៀបចំថវិកាសម្រាប់កិច្ចដំណើរការរបស់ **ន.គ.ស.**
- គ្រប់គ្រងកិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិករបស់ **ន.គ.ស.**
- សម្របសម្រួលការគ្រប់គ្រងធនធានមនុស្សរបស់ **ន.គ.ស.**
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលត្រូវបានបែងចែកឱ្យនៅក្រោម **ន.គ.ស.** និងរៀបចំបញ្ជីសារពើភ័ណ្ឌ
- រៀបចំ ដាក់ឱ្យដំណើរការ និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រង និងការផ្សព្វផ្សាយរបស់ **ន.គ.ស.**
- ទំនាក់ទំនងជាមួយស្ថាប័នជាតិ-អន្តរជាតិ និងវិស័យឯកជន
- ផ្សព្វផ្សាយជាសាធារណៈពីកិច្ចដំណើរការនិងវឌ្ឍនភាពរបស់ **ន.គ.ស.**
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គនាយកនៃ **ន.គ.ស.**។

មាត្រា ៣៥.-

នាយកដ្ឋានបច្ចេកទេស ជាសេនាធិការឱ្យ **ន.គ.ស.** លើតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តផែនការសកម្មភាពការងាររបស់នាយកដ្ឋានបច្ចេកទេស
- សិក្សាស្រាវជ្រាវ និងរៀបចំស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម ក្រមសីលធម៌វិជ្ជាជីវៈ និងស្តង់ដាពាក់ព័ន្ធ
- ពន្យល់ និងបកស្រាយលើទិដ្ឋភាពបច្ចេកទេសនៃស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម ក្រមសីលធម៌វិជ្ជាជីវៈ និងស្តង់ដាពាក់ព័ន្ធ
- ពិនិត្យឡើងវិញលើការអនុវត្តស្តង់ដា និងកំណត់បញ្ហាប្រឈម ទាំងទិដ្ឋភាពបច្ចេកទេស ទិដ្ឋភាពបទប្បញ្ញត្តិ ព្រមទាំងស្នើឡើងនូវដំណោះស្រាយ
- សហការនិងចូលរួមជាមួយស្ថាប័នតំបន់និងអន្តរជាតិ ក្នុងការរៀបចំធ្វើបច្ចុប្បន្នភាព និងអភិវឌ្ឍស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម ក្រមសីលធម៌វិជ្ជាជីវៈ និងស្តង់ដាពាក់ព័ន្ធ
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គនាយកនៃ **ន.គ.ស.**។

មាត្រា ៣៦.-

នាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ជាសេនាធិការឱ្យ **ន.គ.ស.** លើតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តផែនការសកម្មភាពការងាររបស់នាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម
- ពិនិត្យ និងផ្តល់យោបល់លើសំណើសុំអាជ្ញាបណ្ណ ឬការអនុញ្ញាតប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម
- ពិនិត្យ និងផ្តល់យោបល់លើវិធានការចំពោះអំពើល្មើសទៅនឹងបទប្បញ្ញត្តិស្តីពីការផ្តល់អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
- រៀបចំ និងធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិចាំបាច់នានា ទាក់ទងនឹងការផ្តល់អាជ្ញាបណ្ណ ឬការអនុញ្ញាត ប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
- ត្រួតពិនិត្យគុណភាពសេវាគណនេយ្យនិងសវនកម្ម
- រៀបចំ និងគ្រប់គ្រងទិន្នន័យក្រុមហ៊ុនគណនេយ្យ និងក្រុមហ៊ុនសវនកម្ម
- រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា
- រៀបចំ ដាក់ឱ្យដំណើរការ និងគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា
- ចូលរួមអនុវត្តផែនការសកម្មភាពទាក់ទងនឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គនាយកនៃ **ន.គ.ស.**។

មាត្រា ៣៧.-

នាយកដ្ឋានកិច្ចការតតិយុត្ត និងអនុលោមភាព ជាសេនាធិការឱ្យ **ន.គ.ស.** លើតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តផែនការសកម្មភាពការងាររបស់នាយកដ្ឋានកិច្ចការតតិយុត្ត និងអនុលោមភាព
- រៀបចំ និងធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិចាំបាច់នានា
- ពិនិត្យ និងផ្តល់យោបល់លើវិធានការពង្រឹងការអនុវត្តច្បាប់
- រៀបចំនីតិវិធី និងដោះស្រាយបណ្តឹងពាក់ព័ន្ធនឹងវិស័យគណនេយ្យនិងសវនកម្ម
- រៀបចំ និងគ្រប់គ្រងទិន្នន័យអំពីសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ
- ត្រួតពិនិត្យអនុលោមភាពតាមច្បាប់ បទប្បញ្ញត្តិ និងស្តង់ដាពាក់ព័ន្ធ
- គ្រប់គ្រង ត្រួតពិនិត្យទាំងលើឯកសារ និងដល់ទីកន្លែង និងវាយតម្លៃលើរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ
- ចូលរួមអនុវត្តផែនការសកម្មភាពទាក់ទងនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- រៀបចំការបណ្តុះបណ្តាល និងការផ្សព្វផ្សាយច្បាប់ បទប្បញ្ញត្តិ និងស្តង់ដាពាក់ព័ន្ធ
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គនាយកនៃ **ន.គ.ស.**។

ជំពូកទី៨
និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ

មាត្រា ៣៨.-

និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ (សរសេរកាត់ថា **ន.អ.ប.**) បំពេញមុខងារជាសេនាធិការឱ្យ **អ.ស.ហ.។ ន.អ.ប.** មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តនូវគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃវិស័យអចលនវត្ថុ វិស័យបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន
- ត្រួតពិនិត្យ និងតាមដានអនុលោមភាពនៃការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យអចលនវត្ថុ វិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន
- រៀបចំ ធ្វើបច្ចុប្បន្នភាព និងស្នើសុំការអនុម័តច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធសម្រាប់គ្រប់គ្រងវិស័យអចលនវត្ថុ វិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន
- លើកកម្ពស់ការអប់រំ បណ្តុះបណ្តាល និងផ្សព្វផ្សាយដល់សាធារណជន
- ចូលរួមក្នុងកិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិ
- បង្កើត និងគ្រប់គ្រងមូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យអចលនវត្ថុនិងវិស័យបញ្ចាំ តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**
- គ្រប់គ្រងហិរញ្ញវត្ថុ និងបុគ្គលិករបស់ **ន.អ.ប.**
- សម្របសម្រួលការគ្រប់គ្រងធនធានមនុស្ស និងការរៀបចំថវិការបស់ **ន.អ.ប.** ជាមួយអគ្គលេខាធិការដ្ឋាន
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលត្រូវបានបែងចែកឱ្យនៅក្រោម **ន.អ.ប.** និងរៀបចំបញ្ជីសារពើភ័ណ្ឌជូនអគ្គលេខាធិការដ្ឋាន
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

មាត្រា ៣៩.-

អគ្គនាយកនៃ **ន.អ.ប.** មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- ដឹកនាំការអនុវត្តតួនាទី និងភារកិច្ចដូចមានចែងក្នុងមាត្រា ៣៨ នៃអនុក្រឹត្យនេះ
- គ្រប់គ្រងការងារប្រចាំថ្ងៃរបស់ **ន.អ.ប.**
- រៀបចំស្នើឡើង និងអនុវត្តថវិកាប្រចាំឆ្នាំ រួមទាំងការគ្រប់គ្រងចំណូល និងចំណាយសម្រាប់កិច្ចដំណើរការរបស់ **ន.អ.ប.**
- ពិនិត្យពាក្យស្នើសុំអាជ្ញាបណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត និងផ្តល់ ឬមិនផ្តល់អាជ្ញាបណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត នៅពេលដែលអ្នកស្នើសុំបានបំពេញ ឬមិនបានបំពេញតាមលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធវិស័យអចលនវត្ថុវិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន និងលក្ខខណ្ឌផ្សេងទៀតដែលក្រុមប្រឹក្សា **អ.ស.ហ.** បានកំណត់

- ចាត់វិធានការសមស្របដែលច្បាប់ និងបទប្បញ្ញាត្តិពាក់ព័ន្ធវិស័យអចលនវត្ថុវិស័យបញ្ចាំ និងប្រាតិភោគដោយអនុប្បទានអនុញ្ញាត ចំពោះអំពើល្មើសទៅនឹងលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញាត្តិពាក់ព័ន្ធវិស័យអចលនវត្ថុ វិស័យបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន
- ជាតំណាងឱ្យ **ន.អ.ប.** នៅចំពោះមុខតុលាការ ចុះកិច្ចសន្យា និងកិច្ចព្រមព្រៀងផ្សេងៗក្នុងនាម **ន.អ.ប.** ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**
- ជាតំណាងឱ្យ **ន.អ.ប.** ក្នុងកិច្ចទំនាក់ទំនងជាមួយស្ថាប័នជាតិ អន្តរជាតិ និងវិស័យឯកជន
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

មាត្រា ៤០.-

ន.អ.ប. មាននាយកដ្ឋានចំណុះចំនួន ៤ (បួន) ដូចខាងក្រោម÷

- នាយកដ្ឋានកិច្ចការទូទៅ
- នាយកដ្ឋានគ្រប់គ្រងអាជ្ញាបណ្ណ និងកិច្ចការគតិយុត្ត
- នាយកដ្ឋានត្រួតពិនិត្យ
- នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ។

មាត្រា ៤១.-

នាយកដ្ឋានកិច្ចការទូទៅ ជាសេនាធិការឱ្យ **ន.អ.ប.** លើតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តផែនការសកម្មភាពរបស់នាយកដ្ឋានកិច្ចការទូទៅ
- សម្របសម្រួល និងបូកសរុបផែនការសកម្មភាពរួមរបស់ **ន.អ.ប.**
- រៀបចំថវិកាសម្រាប់កិច្ចដំណើរការរបស់ **ន.អ.ប.**
- គ្រប់គ្រងកិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិករបស់ **ន.អ.ប.**
- សម្របសម្រួលការគ្រប់គ្រងធនធានមនុស្សរបស់ **ន.អ.ប.**
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលត្រូវបានបែងចែកឱ្យនៅក្រោម **ន.អ.ប.** និងរៀបចំបញ្ជីសារពើភ័ណ្ឌ
- រៀបចំ ដាក់ឱ្យដំណើរការនិងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រង និងផ្សព្វផ្សាយរបស់ **ន.អ.ប.**
- ទំនាក់ទំនងជាមួយស្ថាប័នជាតិ-អន្តរជាតិ និងវិស័យឯកជន
- ផ្សព្វផ្សាយជាសាធារណៈពីកិច្ចដំណើរការ និងវឌ្ឍនភាព របស់ **ន.អ.ប.**
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គនាយកនៃ **ន.អ.ប.**។

មាត្រា ៤២.-

នាយកដ្ឋានគ្រប់គ្រងអាជ្ញាបណ្ណនិងកិច្ចការគតិយុត្ត ជាសេនាធិការឱ្យ **ន.អ.ប.** លើតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តផែនការសកម្មភាពរបស់នាយកដ្ឋានគ្រប់គ្រងអាជ្ញាបណ្ណ និងកិច្ចការគតិយុត្ត
- ពិនិត្យ និងផ្តល់យោបល់លើការសុំអាជ្ញាបណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតនៃអាជីវកម្មអចលនវត្ថុ អាជីវកម្មបញ្ចាំ និងអាជីវកម្មប្រាតិភោគដោយអនុប្បទាន ឬអាជីវកម្មគាំទ្រ
- ពិនិត្យ និងផ្តល់យោបល់លើការសុំផ្លាស់ប្តូរនាមករណ៍ និមិត្តសញ្ញា អាសយដ្ឋាន សមាជិកភាគហ៊ុន នៃអាជីវកម្មអចលនវត្ថុ អាជីវកម្មបញ្ចាំនិងអាជីវកម្មប្រាតិភោគដោយអនុប្បទាន ឬអាជីវកម្មគាំទ្រ
- ពិនិត្យ និងផ្តល់យោបល់លើវិធានការចំពោះអំពើល្មើសទៅនឹងបទប្បញ្ញត្តិពាក់ព័ន្ធនឹងអាជ្ញាបណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតនៃអាជីវកម្មអចលនវត្ថុ អាជីវកម្មបញ្ចាំនិងអាជីវកម្មប្រាតិភោគដោយអនុប្បទាន ឬអាជីវកម្មគាំទ្រ
- រៀបចំ និងធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិទាក់ទងនឹងការផ្តល់អាជ្ញាបណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតនៃអាជីវកម្មអចលនវត្ថុ អាជីវកម្មបញ្ចាំនិងអាជីវកម្មប្រាតិភោគដោយអនុប្បទាន ឬអាជីវកម្មគាំទ្រ
- ពិនិត្យ និងផ្តល់យោបល់លើទម្រង់ និងខ្លឹមសារនៃបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យអចលនវត្ថុ វិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន ឬអាជីវកម្មគាំទ្ររបស់ **ន.អ.ប.**
- រៀបចំនីតិវិធីនិងដោះស្រាយបណ្តឹងនៃអាជីវកម្មអចលនវត្ថុ អាជីវកម្មបញ្ចាំនិងអាជីវកម្មប្រាតិភោគដោយអនុប្បទាន ឬអាជីវកម្មគាំទ្រ
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គនាយកនៃ **ន.អ.ប.**។

មាត្រា ៤៣.-

នាយកដ្ឋានត្រួតពិនិត្យ ជាសេនាធិការឱ្យ **ន.អ.ប** លើតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តផែនការសកម្មភាពការងាររបស់នាយកដ្ឋានត្រួតពិនិត្យ
- ត្រួតពិនិត្យលើឯកសារ និងតាមដានលើស្ថានភាពហានិភ័យហិរញ្ញវត្ថុប្រចាំគ្រារបស់អាជីវកម្មអចលនវត្ថុ អាជីវកម្មបញ្ចាំនិងអាជីវកម្មប្រាតិភោគដោយអនុប្បទាន ឬអាជីវកម្មគាំទ្រ
- ត្រួតពិនិត្យដល់ទីកន្លែងចំពោះអាជីវកម្មអចលនវត្ថុ អាជីវកម្មបញ្ចាំនិងអាជីវកម្មប្រាតិភោគដោយអនុប្បទាន ឬអាជីវកម្មគាំទ្រ
- រៀបចំ និងធ្វើបច្ចុប្បន្នភាពនៃលិខិតបទដ្ឋានគតិយុត្ត ក្នុងក្របខ័ណ្ឌត្រួតពិនិត្យស្ថានភាពហិរញ្ញវត្ថុនៃការធ្វើអាជីវកម្មអចលនវត្ថុ អាជីវកម្មបញ្ចាំនិងអាជីវកម្មប្រាតិភោគដោយអនុប្បទាន ឬអាជីវកម្មគាំទ្រ
- ពិនិត្យ និងផ្តល់យោបល់លើការសុំតែងតាំងឬផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល ឬអនុញ្ញាតបង្កើន ឬបន្ថយដើមទុនចុះបញ្ជីនៃអាជីវកម្មអចលនវត្ថុ អាជីវកម្មបញ្ចាំនិងអាជីវកម្មប្រាតិភោគដោយអនុប្បទាន ឬអាជីវកម្មគាំទ្រ

- ពិនិត្យ និងផ្តល់យោបល់លើវិធានការចំពោះអំពើល្មើសទៅនឹងបទប្បញ្ញត្តិក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យស្ថានភាពហិរញ្ញវត្ថុនៃអាជីវកម្មអចលនវត្ថុ អាជីវកម្មបញ្ចាំនិងអាជីវកម្មប្រាតិភោគដោយអនុប្បទាន ឬអាជីវកម្មគាំទ្រ
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គនាយកនៃ **ន.អ.ប.**។

មាត្រា ៤៤.-

នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ ជាសេនាធិការឱ្យអគ្គនាយក នៃ **ន.អ.ប.** លើតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តផែនការសកម្មភាពការងាររបស់នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ
- សិក្សាស្រាវជ្រាវ និងរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យអចលនវត្ថុ វិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន
- រៀបចំ និងគ្រប់គ្រងទិន្នន័យនៃអាជីវកម្មអចលនវត្ថុ អាជីវកម្មបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន ឬអាជីវកម្មគាំទ្រ
- រៀបចំការបណ្តុះបណ្តាល និងការផ្សព្វផ្សាយ ដើម្បីបង្កើនការយល់ដឹងរបស់សាធារណជន
- សហការជាមួយនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ នៃបណ្តាប្រទេសផ្សេងទៀត និងដៃគូពាក់ព័ន្ធជាតិនិងអន្តរជាតិ
- ចូលរួមអនុវត្តផែនការសកម្មភាពទាក់ទងនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ការពង្រឹងស្ថិរភាពហិរញ្ញវត្ថុ និងការជំរុញបរិយាប័ន្នហិរញ្ញវត្ថុ
- រៀបចំ និងផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំអំពីវិស័យអចលនវត្ថុ វិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គនាយកនៃ **ន.អ.ប.**។

ជំពូកទី៩
អង្គភាពសវនកម្មផ្ទៃក្នុង

មាត្រា ៤៥.-

អង្គភាពសវនកម្មផ្ទៃក្នុងបំពេញមុខងារជាសេនាធិការជូនក្រុមប្រឹក្សា **អ.ស.ហ.** និងប្រធានក្រុមប្រឹក្សា **អ.ស.ហ.** លើការងារសវនកម្ម។ អង្គភាពសវនកម្មផ្ទៃក្នុងមានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់អង្គភាពសវនកម្មផ្ទៃក្នុង
- រៀបចំ និងស្នើដាក់ឱ្យអនុវត្តនូវយន្តការ គោលការណ៍ និងបញ្ជីត្រួតពិនិត្យ ក្នុងការពិនិត្យឡើងវិញ និងក្នុងការធ្វើសវនកម្ម
- ពិនិត្យឡើងវិញលើមុខងារ កម្មវិធីការងារ សកម្មភាព និងកិច្ចប្រតិបត្តិការរបស់អង្គភាពក្រោមឱវាទ **អ.ស.ហ.**

- ពិនិត្យឡើងវិញលើភាពត្រឹមត្រូវ ភាពសមស្រប ភាពគ្រប់គ្រាន់ នូវអនុលោមភាព សមិទ្ធិកម្ម ធនធានមនុស្ស ទ្រព្យសកម្ម ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងហិរញ្ញវត្ថុ របស់អង្គភាពក្រោមឱវាទ **អ.ស.ហ.**
- ធ្វើសវនកម្មលើភាពត្រឹមត្រូវ ភាពសមស្រប ភាពគ្រប់គ្រាន់ នូវអនុលោមភាព សមិទ្ធិកម្ម ធនធានមនុស្ស ទ្រព្យសកម្ម ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងហិរញ្ញវត្ថុរបស់អង្គភាព ក្រោមឱវាទ **អ.ស.ហ.** និងរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**
- ធ្វើសវនកម្មលើការអនុវត្តបទបញ្ជាផ្ទៃក្នុងស្តីពីការគ្រប់គ្រងមន្ត្រីជំនាញគ្រប់ជាន់ថ្នាក់របស់ **អ.ស.ហ.** និងលើការអនុវត្តលក្ខន្តិកៈនៃមន្ត្រីរបស់ **អ.ស.ហ.**
- តាមដានការអនុវត្តតាមអនុសាសន៍របស់សវនករផ្ទៃក្នុង
- រៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាលពាក់ព័ន្ធមុខងារសវនកម្មផ្ទៃក្នុង
- គ្រប់គ្រងហិរញ្ញវត្ថុ និងបុគ្គលិករបស់អង្គភាពសវនកម្មផ្ទៃក្នុង
- សម្របសម្រួលការគ្រប់គ្រងធនធានមនុស្សរបស់អង្គភាពសវនកម្មផ្ទៃក្នុង ជាមួយអគ្គលេខាធិការដ្ឋាន
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលត្រូវបានបែងចែកឱ្យនៅក្រោមអង្គភាពសវនកម្មផ្ទៃក្នុង និងរៀបចំបញ្ជីសារពើភ័ណ្ឌជូនអគ្គលេខាធិការដ្ឋាន
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

មាត្រា ៤៦.-

ប្រធានអង្គភាពសវនកម្មផ្ទៃក្នុងមានតួនាទី និងភារកិច្ចដូចតទៅ÷

- ដឹកនាំ និងអនុវត្តតួនាទី និងភារកិច្ចដូចមានចែងក្នុងមាត្រា ៤៥ នៃអនុក្រឹត្យនេះ
- គ្រប់គ្រងការងារប្រចាំថ្ងៃរបស់អង្គភាពសវនកម្មផ្ទៃក្នុង
- គ្រប់គ្រង និងអនុវត្តថវិកាប្រចាំឆ្នាំរបស់អង្គភាពសវនកម្មផ្ទៃក្នុង
- ជាតំណាងឱ្យអង្គភាពសវនកម្មផ្ទៃក្នុង ក្នុងកិច្ចទំនាក់ទំនងជាមួយស្ថាប័នជាតិ-អន្តរជាតិ
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

មាត្រា ៤៧.-

អង្គភាពសវនកម្មផ្ទៃក្នុង មាននាយកដ្ឋានចំណុះចំនួន ៣ (បី) ដូចខាងក្រោម÷

- នាយកដ្ឋានកិច្ចការទូទៅ
- នាយកដ្ឋានសវនកម្មទី១
- នាយកដ្ឋានសវនកម្មទី២។

មាត្រា ៤៨.-

នាយកដ្ឋានកិច្ចការទូទៅ ជាសេនាធិការឱ្យប្រធានអង្គភាពសវនកម្មផ្ទៃក្នុង មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំផែនការយុទ្ធសាស្ត្ររបស់អង្គភាពសវនកម្មផ្ទៃក្នុង
- រៀបចំ និងអនុវត្តផែនការសកម្មភាពរបស់នាយកដ្ឋានកិច្ចការទូទៅ
- សម្របសម្រួល និងបូកសរុបផែនការសម្មភាព និងរបាយការណ៍របស់អង្គភាពសវនកម្មផ្ទៃក្នុង
- គ្រប់គ្រងថវិកាសម្រាប់កិច្ចដំណើរការរបស់អង្គភាពសវនកម្មផ្ទៃក្នុង
- គ្រប់គ្រងការងាររដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិករបស់ អង្គភាពសវនកម្មផ្ទៃក្នុង
- សម្របសម្រួលការគ្រប់គ្រងធនធានមនុស្សរបស់អង្គភាពសវនកម្មផ្ទៃក្នុង ជាមួយអគ្គលេខាធិការដ្ឋាន
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលត្រូវបានបែងចែកឱ្យនៅក្រោមអង្គភាពសវនកម្មផ្ទៃក្នុង និងរៀបចំបញ្ជីសារពើភ័ណ្ឌ
- រៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាល ពាក់ព័ន្ធមុខងារសវនកម្មផ្ទៃក្នុង
- ប្រមូល និងតាមដានជាប្រចាំនូវឯកសារគតិយុត្ត និងសកម្មភាពកែទម្រង់ផ្សេងៗរបស់អង្គភាពក្រោមឱវាទ **អ.ស.ហ.**
- រៀបចំ ដាក់ឱ្យដំណើរការ និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រង និងផ្សព្វផ្សាយរបស់អង្គភាពសវនកម្មផ្ទៃក្នុង
- ទំនាក់ទំនងជាមួយស្ថាប័នជាតិ-អន្តរជាតិ
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់ប្រធានអង្គភាពសវនកម្មផ្ទៃក្នុង។

មាត្រា ៤៩.-

នាយកដ្ឋានសវនកម្មទី ១ និងនាយកដ្ឋានសវនកម្មទី ២ ជាសេនាធិការឱ្យប្រធានអង្គភាពសវនកម្មផ្ទៃក្នុង មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តផែនការសកម្មភាពរបស់នាយកដ្ឋាន
- រៀបចំ និងស្នើដាក់ឱ្យអនុវត្តនូវយន្តការ គោលការណ៍ និងបញ្ជីត្រួតពិនិត្យ ក្នុងការពិនិត្យឡើងវិញ និងក្នុងការធ្វើសវនកម្ម
- រៀបចំ និងស្នើដាក់ឱ្យអនុវត្តស្តង់ដាក្រមសីលធម៌របស់អង្គភាពសវនកម្មផ្ទៃក្នុង
- សិក្សា និងរៀបចំស្តង់ដាគ្រប់គ្រងពាក់ព័ន្ធអនុលោមភាព សមិទ្ធិកម្ម ធនធានមនុស្ស ទ្រព្យសកម្ម ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងហិរញ្ញវត្ថុ
- ពិនិត្យឡើងវិញលើមុខងារ កម្មវិធីការងារ សកម្មភាព និងកិច្ចប្រតិបត្តិការរបស់អង្គភាពក្រោមឱវាទ **អ.ស.ហ.**

- ពិនិត្យឡើងវិញលើភាពត្រឹមត្រូវ ភាពសមស្រប ភាពគ្រប់គ្រាន់ នូវអនុលោមភាព សមិទ្ធិកម្ម ធនធានមនុស្ស ទ្រព្យសកម្ម ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងហិរញ្ញវត្ថុរបស់អង្គភាពក្រោមឱវាទ **អ.ស.ហ.**
- ធ្វើសវនកម្មលើភាពត្រឹមត្រូវ ភាពសមស្រប ភាពគ្រប់គ្រាន់ នូវអនុលោមភាព សមិទ្ធិកម្ម ធនធានមនុស្ស ទ្រព្យសកម្ម ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងហិរញ្ញវត្ថុរបស់អង្គភាព ក្រោមឱវាទ **អ.ស.ហ.**
- ធ្វើសវនកម្មលើការអនុវត្តបទបញ្ជាផ្ទៃក្នុងស្តីពីការគ្រប់គ្រងមន្ត្រីជំនាញគ្រប់ជាន់ថ្នាក់របស់ **អ.ស.ហ.** និងលើការអនុវត្តលក្ខន្តិកៈនៃមន្ត្រីរបស់ **អ.ស.ហ.**
- តាមដានការអនុវត្តតាមអនុសាសន៍របស់សវនករផ្ទៃក្នុង
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់ប្រធានអង្គភាពសវនកម្មផ្ទៃក្នុង។

ជំពូកទី១០
មន្ត្រីរបស់ **អ.ស.ហ.**

មាត្រា ៥០.-

មន្ត្រីរបស់អង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.** រួមមាន÷

- មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ និង
- មន្ត្រីលក្ខន្តិកៈរបស់ **អ.ស.ហ.**។

លក្ខន្តិកៈនៃមន្ត្រីលក្ខន្តិកៈរបស់ **អ.ស.ហ.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

មាត្រា ៥១.-

អង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.** អាចជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា អ្នកជំនាញការជាតិ និងអ្នកជំនាញការបរទេស សម្រាប់ជួយការងារស្របតាមតម្រូវការជាក់ស្តែង ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** តាមសំណើរបស់អង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.** ក្រោមកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាន។

មាត្រា ៥២.-

ប្រាក់បៀវត្ស និងលាភការសម្រាប់មន្ត្រីលក្ខន្តិកៈរបស់ **អ.ស.ហ.** មន្ត្រីជាប់កិច្ចសន្យា អ្នកជំនាញការជាតិ និងអ្នកជំនាញការបរទេស និងប្រាក់បំណាច់បន្ថែមរបស់មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈដែលបំពេញការងារនៅតាមអង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.** ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** តាមសំណើរបស់អង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.** ក្រោមកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាន។

ជំពូកទី១១
ប្រភពធនធាន និងការគ្រប់គ្រងហិរញ្ញវត្ថុ

មាត្រា ៥៣.-

អគ្គលេខាធិការដ្ឋាន និងនិយ័តករនីមួយៗនៃ **អ.ស.ហ.** មានកញ្ចប់ថវិកាដោយឡែកសម្រាប់គាំទ្រដល់កិច្ចដំណើរការរបស់ខ្លួន។ និយ័តករសន្តិសុខសង្គមប្រើប្រាស់កញ្ចប់ថវិការួមជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីបំពេញភារកិច្ចនាទីប្រចាំថ្ងៃរបស់ខ្លួន។

អគ្គលេខាធិការដ្ឋាន និងនិយ័តករនីមួយៗនៃ **អ.ស.ហ.** ត្រូវស្នើសុំការពិនិត្យនិងអនុម័តថវិកាប្រចាំឆ្នាំរបស់ខ្លួនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈក្រុមប្រឹក្សា **អ.ស.ហ.** លើកលែងតែនិយ័តករសន្តិសុខសង្គម ដូចកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ និងអង្គភាពសវនកម្មផ្ទៃក្នុងដែលត្រូវរៀបចំថវិកាជាកញ្ចប់ជាមួយអគ្គលេខាធិការដ្ឋាន។

ប្រភពថវិការបស់អង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.** រួមមាន÷

- ថវិការដ្ឋ
- ថវិកាពីប្រភពស្របច្បាប់ផ្សេងទៀត។

មាត្រា ៥៤.-

អង្គភាពក្រោមឱវាទ **អ.ស.ហ.** អាចមានប្រភពធនធានផ្សេងទៀត ដូចជាកម្រៃអាជ្ញាបណ្ណ វិញ្ញាបនបត្រ ការអនុញ្ញាត ការទទួលស្គាល់ ការចុះបញ្ជីនិងលិខិតអនុញ្ញាត សោហ៊ុយសិក្សានិងពិនិត្យពាក្យស្នើសុំអាជ្ញាបណ្ណ វិញ្ញាបនបត្រ ការអនុញ្ញាត ការទទួលស្គាល់ ការចុះបញ្ជីនិងលិខិតអនុញ្ញាត កម្រៃនៃការផ្តល់សេវាសាធារណៈ និងប្រាក់ផាកពិន័យ។ ប្រភពធនធានលម្អិតរបស់អង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.** និងការប្រើប្រាស់ប្រភពធនធាននេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

មាត្រា ៥៥.-

ធនធានហិរញ្ញវត្ថុពីប្រភពផ្សេងៗរបស់អង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.** ត្រូវបានដាក់ចូលក្នុងគណនីទោលរបស់រតនាគារ លើកលែងតែមានបដិប្បញ្ញត្តិដែលត្រូវមានការយល់ព្រមដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា ៥៦.-

លាភការរបស់ប្រធាន អនុប្រធាន និងសមាជិកក្រុមប្រឹក្សា **អ.ស.ហ.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

មាត្រា ៥៧.-

អ.ស.ហ. មានសិទ្ធិទទួល និងគ្រប់គ្រងជាកម្មសិទ្ធិករនូវចលនវត្ថុ និងអចលវត្ថុដែលជាអំណោយឬអច្ចិយទានរបស់ឯកជន និងអំណោយរបស់រដ្ឋ។

ជំពូកទី១២
បទប្បញ្ញត្តិផ្សេងៗ

មាត្រា ៥៨. -

អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** ត្រូវដឹកនាំដោយអគ្គលេខាធិការ ១ (មួយ) រូប អមដោយអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់។

និយ័តករនីមួយៗនៃ **អ.ស.ហ.** ត្រូវដឹកនាំដោយអគ្គនាយក ១ (មួយ) រូប អមដោយអគ្គនាយករង មួយចំនួនតាមការចាំបាច់។

អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** ត្រូវដឹកនាំដោយប្រធាន ១ (មួយ) រូប និងអនុប្រធានមួយចំនួនតាមការចាំបាច់។

អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន អគ្គនាយករងនៃនិយ័តករពាក់ព័ន្ធ និងអនុប្រធានអង្គភាពសវនកម្មផ្ទៃក្នុង មានសិទ្ធិអំណាច និងបំពេញភារកិច្ចទាំងឡាយ ដែលអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃនិយ័តករពាក់ព័ន្ធ និងប្រធានអង្គភាពសវនកម្មផ្ទៃក្នុង ប្រគល់ឱ្យ។

មាត្រា ៥៩.-

នាយកដ្ឋាននីមួយៗ និងមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋាន អង្គភាពសវនកម្មផ្ទៃក្នុង និងនិយ័តករពាក់ព័ន្ធ ត្រូវដឹកនាំដោយប្រធាន ១ (មួយ) រូបដែលមានឋានៈ និងបុព្វសិទ្ធិស្មើប្រធាននាយកដ្ឋាន និងអនុប្រធានមួយចំនួនជាជំនួយការដែលមានឋានៈ និងបុព្វសិទ្ធិស្មើអនុប្រធាននាយកដ្ឋាន និងមានការិយាល័យចំណុះមួយចំនួន តាមការចាំបាច់។

អង្គការលេខ និងនិមិត្តសញ្ញារបស់ **អ.ស.ហ.** អគ្គលេខាធិការដ្ឋាន អង្គភាពសវនកម្មផ្ទៃក្នុង ព្រមទាំងនិយ័តករពាក់ព័ន្ធ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា ៦០.-

ប្រធាននាយកដ្ឋានត្រូវតែងតាំង ឬផ្លាស់ប្តូរភារកិច្ចដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។ ការតែងតាំង ឬការផ្លាស់ប្តូរភារកិច្ចចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋានចុះ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** តាមសំណើរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ប្រធានអង្គភាពសវនកម្មផ្ទៃក្នុង និងអគ្គនាយកនៃនិយ័តករពាក់ព័ន្ធ។

មាត្រា ៦១.-

ការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់អគ្គលេខាធិការដ្ឋាន អង្គភាពសវនកម្មផ្ទៃក្នុង និងនិយ័តករពាក់ព័ន្ធត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

មាត្រា ៦២.-

អគ្គលេខាធិការដ្ឋាន មានសិទ្ធិប្រើប្រាស់និមិត្តសញ្ញា និងត្រារបស់ **អ.ស.ហ.** ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

និយ័តករ និងអង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** មាននិមិត្តសញ្ញា និងត្រាដោយឡែក ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

ជំពូកទី១៣
អវសានប្បញ្ញត្តិ

មាត្រា ៦៣.-

អនុក្រឹត្យលេខ១៨៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ ត្រូវជំនួសដោយអនុក្រឹត្យនេះ។

មាត្រា ៦៤.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា ៦៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៤ រោចខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ជូនមាត្រា៦៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

និមិត្តសញ្ញារបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

អត្ថន័យ÷

និមិត្តសញ្ញារបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ មានអត្ថន័យដូចខាងក្រោម÷

- **រូបស្តេចហង្សមួយគូ និងរូបគោព្រៃពណិមាស÷** តំណាងឱ្យអាជ្ញាធរសេវាហិរញ្ញវត្ថុរបស់ព្រះរាជាណាចក្រកម្ពុជា ដែលជាអ្នកគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមមាន វិស័យធានារ៉ាប់រងនិងសោធនឯកជន វិស័យមូលបត្រ វិស័យសន្តិសុខសង្គម វិស័យបរធនបាលកិច្ច វិស័យគណនេយ្យនិងសវនកម្ម និងវិស័យអចលនវត្ថុ វិស័យបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ប្រកបដោយថាមភាព វឌ្ឍនភាព គណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងយុត្តិធម៌ ឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន ចីរភាព ភាពរឹងមាំ ភាពធន់ និងនវានុវត្តន៍
- **អក្សរកាត់ អ.ស.ហ. ឬ FSA÷** តំណាងឱ្យអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- **រូបសញ្ញាគ្រាហ្វិកពណិបៃតង÷** បង្ហាញពីជវភាពនៃវិស័យហិរញ្ញវត្ថុ និងប្រតិបត្តិការទីផ្សារ ដែលមានការប្រែប្រួល ឡើងចុះ ក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់អាជ្ញាធរ។

ឧបសម្ព័ន្ធទី២
នៃអនុក្រឹត្យលេខ១១៣អនុក្រ.បក ចុះថ្ងៃទី..១៤..ខែ.កក្កដា...ឆ្នាំ២០.២១..
ស្តីពីអង្គការលេខ និងនិមិត្តសញ្ញារបស់
អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

* * * *

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន



និមិត្តសញ្ញារបស់អគ្គលេខាធិការដ្ឋាន

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ប្រើនិមិត្តសញ្ញា និងត្រារបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

និមិត្តសញ្ញារបស់និយ័តករធានារ៉ាប់រងកម្ពុជា

អត្ថន័យ÷

និមិត្តសញ្ញារបស់និយ័តករធានារ៉ាប់រងកម្ពុជាមានអត្ថន័យដូចខាងក្រោម÷

- **រូបហង្សពណ៌មាស÷** តំណាងឱ្យអាជ្ញាធរហិរញ្ញវត្ថុដែលជាអ្នកគ្រប់គ្រង ត្រួតពិនិត្យប្រតិបត្តិការធានារ៉ាប់រងនិងសោធនឯកជន និងធានាឱ្យដំណើរការទីផ្សារធានារ៉ាប់រងនិងសោធនឯកជនប្រកបដោយតម្លាភាព ប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងយុត្តិធម៌
- **រូបខែលនិងអក្សរ ន.ធ.ក.÷** តំណាងឱ្យការការពារលើការបាត់បង់ផ្នែកហិរញ្ញវត្ថុ នៅពេលដែលមានហានិភ័យកើតឡើង (ធានារ៉ាប់រង) និងតំណាងឱ្យនិយ័តករធានារ៉ាប់រងកម្ពុជា
- **រូបហង្សពណ៌មាសឈរលើខែល÷** បង្ហាញពីដំណើរការនៃទីផ្សារធានារ៉ាប់រងនិងសោធនឯកជន ស្ថិតក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់និយ័តករធានារ៉ាប់រងកម្ពុជា ប្រកបដោយតម្លាភាព ប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងយុត្តិធម៌
- **រូបស្លឹកឈើ÷** លទ្ធផលជាផ្លែផ្កានៃការចូលរួមចំណែករបស់វិស័យធានារ៉ាប់រងនិងសោធនឯកជន ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

ឧបសម្ព័ន្ធទី៣

នៃអនុក្រឹត្យលេខ២១៧អនក្រ/ប៊ីអរ ចុះថ្ងៃទី.១៤...ខែ.កក្កដា....ឆ្នាំ.ឆស.ព.ស.២៥៦៥...

ស្តីពីអង្គការលេខ និងនិមិត្តសញ្ញារបស់និយ័តករដ្ឋាភិបាលកម្ពុជា

* * * *

អង្គការលេខរបស់និយ័តករដ្ឋាភិបាលកម្ពុជា



និមិត្តសញ្ញារបស់និយ័តករមូលបត្រកម្ពុជា

អត្ថន័យ÷

និមិត្តសញ្ញារបស់និយ័តករមូលបត្រកម្ពុជា មានអត្ថន័យដូចខាងក្រោម÷

- **រូបហង្សពណ៌មាស÷** តំណាងឱ្យអាជ្ញាធរហិរញ្ញវត្ថុដែលជាអ្នកគ្រប់គ្រង និងត្រួតពិនិត្យប្រតិបត្តិការមូលបត្រ និងធានាឱ្យដំណើរការទីផ្សារមូលបត្រ ប្រកបដោយតម្លាភាព ប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងយុត្តិធម៌
- **រូបរង្វង់មូលដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ÷** តំណាងឱ្យការចំណេញ ខាត ឬការឡើង ចុះនៃដំណើរការទីផ្សារ
- **រូបហង្សពណ៌មាសឈរលើរង្វង់មូល ដែលមានជើងម្ខាងជាន់លើផ្ទៃពណ៌មាស និងជើងម្ខាងជាន់លើផ្ទៃពណ៌ប្រផេះ÷** បង្ហាញពីការចំណេញ ខាត ឬការឡើង ចុះនៃដំណើរការទីផ្សារ ស្ថិតនៅក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់និយ័តករមូលបត្រកម្ពុជា ប្រកបដោយតម្លាភាព ប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងយុត្តិធម៌
- **រូបស្លឹកឈើ÷** លទ្ធផលជាផ្លែផ្កានៃការចូលរួមចំណែករបស់វិស័យមូលបត្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

ឧបសម្ព័ន្ធទី៤

នៃអនុក្រឹត្យលេខ...ចុះថ្ងៃទី.១៤...ខែ.កក្កដា...ឆ្នាំ.ឆ្នៀ.ព.ស.២៥៦១..

ស្តីពីអង្គការលេខ និងនិមិត្តសញ្ញារបស់និយ័តករមូលបត្រកម្ពុជា

* * * *

អង្គការលេខនៃនិយ័តករមូលបត្រកម្ពុជា



ឧបសម្ព័ន្ធទី៥

នៃអនុក្រឹត្យលេខ.១២៣.អនក្រ/បក ចុះថ្ងៃទី.១៤...ខែ.កក្កដា....ឆ្នាំ.ឆ២០.ឆ១..

ស្តីពីនិមិត្តសញ្ញារបស់និយ័តករសន្តិសុខសង្គម

* * * *

និមិត្តសញ្ញារបស់និយ័តករសន្តិសុខសង្គម

អត្ថន័យ÷

និមិត្តសញ្ញារបស់និយ័តករសន្តិសុខសង្គម មានអត្ថន័យដូចខាងក្រោម÷

- **រូបហង្សពីរពណ៌មាស÷** តំណាងឱ្យអាជ្ញាធរហិរញ្ញវត្ថុ ដែលជាអ្នកគ្រប់គ្រង និងត្រួតពិនិត្យប្រព័ន្ធសន្តិសុខសង្គម ដើម្បីធានាដំណើរការប្រតិបត្តិការនៃរបបសន្តិសុខសង្គម ប្រកបដោយតម្លាភាព ប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងយុត្តិធម៌
- **រូបដំបូលរចនាតាមក្បាច់ចម្លាក់ខ្មែរ÷** តំណាងឱ្យប្រព័ន្ធសន្តិសុខសង្គមនៅកម្ពុជា ដែលជាសសរស្តម្ភសំខាន់មួយនៃប្រព័ន្ធការពារសង្គមសម្រាប់ប្រជាជន ទល់នឹងហានិភ័យផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **រូបមនុស្សក្រោមដំបូល÷** តំណាងឱ្យប្រជាជនក្នុងវ័យ ក្រុម និងភេទផ្សេងគ្នាទទួលផលពីរបបសន្តិសុខសង្គម ដែលរួមចំណែកកាត់បន្ថយ និងទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព។

ឧបសម្ព័ន្ធទី៦

នៃអនុក្រឹត្យលេខ២៣៧អនក្រ/បីឆ្នាំថ្ងៃទី..១៤...ខែ.កក្កដា....ឆ្នាំ.ជ២០.ស.១..

ស្តីពីអង្គការលេខ និងនិមិត្តសញ្ញារបស់និយ័តករបរឆនចាលកិច្ច

* * * *

អង្គការលេខរបស់និយ័តករបរឆនចាលកិច្ច



និមិត្តសញ្ញារបស់និយ័តករបរធនបាលកិច្ច

អត្ថន័យ÷

និមិត្តសញ្ញារបស់និយ័តករបរធនបាលកិច្ចមានអត្ថន័យដូចខាងក្រោម÷

- **រូបហត្ថពណ៌មាស÷** តំណាងឱ្យអាជ្ញាធរហិរញ្ញវត្ថុដែលជាអ្នកគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យបរធនបាលកិច្ច ដើម្បីធានាឱ្យដំណើរការប្រតិបត្តិការបរធនបាលកិច្ច ប្រកបដោយតម្លាភាព ប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងយុត្តិធម៌
- **រូបឆាតដៃចាំងបី ដែលមានពណ៌ខៀវ ពណ៌មាស និងពណ៌បៃតង ស្រោកចូលគ្នា÷** តំណាងឱ្យប្រតិបត្តិការបរធនបាលកិច្ច ដែលក្នុងនោះ បរធនបាលគ្រប់គ្រងនិងថែរក្សាជំនួសបរធន ដែលផ្តល់ដោយបរធនបាលទាយក សម្រាប់ជាប្រយោជន៍ដល់អត្ថគាហក:
- **រូបហត្ថពណ៌មាសឈរលើរូបឆាតដៃបី÷** បង្ហាញពីប្រតិបត្តិការបរធនបាលកិច្ចស្ថិតនៅក្រោមការគ្រប់គ្រងនិងត្រួតពិនិត្យរបស់និយ័តករបរធនបាលកិច្ច ប្រកបដោយតម្លាភាព ប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងយុត្តិធម៌
- **រូបស្លឹកឈើ÷** លទ្ធផលជាផ្លែផ្កានៃការចូលរួមចំណែករបស់វិស័យបរធនបាលកិច្ចក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

ឧបសម្ព័ន្ធទី៧

នៃអនុក្រឹត្យលេខ២៣៧អនក្រ/ប៊ីរ៉ែ ថ្ងៃទី..១.៤...ខែ.កក្កដ.ា...ឆ្នាំ.២០.២១...

ស្តីពីអង្គការលេខ និងនិមិត្តសញ្ញារបស់និយ័តករគណនេយ្យនិងសវនកម្ម

* * * *

អង្គការលេខរបស់និយ័តករគណនេយ្យនិងសវនកម្ម



និមិត្តសញ្ញារបស់និយ័តករគណនេយ្យនិងសវនកម្ម

អត្ថន័យ÷

និមិត្តសញ្ញារបស់និយ័តករគណនេយ្យនិងសវនកម្ម មានអត្ថន័យដូចខាងក្រោម÷

- **រូបរាជសីហ៍និងហង្សពណ៌មាស** ÷ តំណាងឱ្យអាជ្ញាធរហិរញ្ញវត្ថុដែលជាអ្នកគ្រប់គ្រង និងត្រួតពិនិត្យវិស័យគណនេយ្យនិងសវនកម្ម ប្រកបដោយតម្លាភាព ប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងយុត្តិធម៌
- **រូបជើងពានទ្រពន្លឺឆកណ្តោងទ្បឹ**÷ តំណាងឱ្យមូលដ្ឋានគ្រឹះរឹងមាំនៃច្បាប់ បទប្បញ្ញត្តិ ស្តង់ដា និងក្រមសីលធម៌ ក្នុងការទ្រទ្រង់វិស័យគណនេយ្យនិងសវនកម្ម
- **អក្សរ ន.ស.គ.**÷ តំណាងឱ្យឈ្មោះនិយ័តករគណនេយ្យនិងសវនកម្ម
- **រូបស្លឹកឈើ** ÷ លទ្ធផលជាផ្លែផ្កានៃការចូលរួមចំណែករបស់វិស័យគណនេយ្យនិងសវនកម្ម ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

ឧបសម្ព័ន្ធទី៨

នៃអនុក្រឹត្យលេខ២២៣អនក្រ/បីប្រ ថ្ងៃទី.១៨..ខែ.កក្កដា....ឆ្នាំ.ឆ.ស.២.ស.១...

ស្តីពីអង្គការលេខ និងនិមិត្តសញ្ញារបស់និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ជាំ

* * * *

អង្គការលេខរបស់និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ជាំ



និមិត្តសញ្ញារបស់និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ

អត្ថន័យ÷

និមិត្តសញ្ញារបស់និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ មានអត្ថន័យដូចខាងក្រោម÷

- **រូបហត្ថពីរពណ៌មាស÷** តំណាងឱ្យអាជ្ញាធរហិរញ្ញវត្ថុ ដែលជាអ្នកគ្រប់គ្រង និងត្រួតពិនិត្យវិស័យអចលនវត្ថុនិងវិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន ដើម្បីធានាឱ្យដំណើរការប្រតិបត្តិការអាជីវកម្មអចលនវត្ថុនិងអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ប្រកបដោយតម្លាភាព ប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងយុត្តិធម៌
- **រូបផ្ទះ អគារ និងរូបសញ្ញាឆូត÷** តំណាងឱ្យការអភិវឌ្ឍអាជីវកម្មអភិវឌ្ឍន៍អចលនវត្ថុ អាជីវកម្មបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន និងសេវាកម្មពាក់ព័ន្ធ
- **អក្សរ ន.អ.ប.÷** តំណាងឱ្យនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ។

ឧបសម្ព័ន្ធទី៩

នៃអនុក្រឹត្យលេខ១២៣អនក្រ/បី ចុះថ្ងៃទី..១៤...ខែ.កក្កដា...ឆ្នាំ២០២១...

ស្តីពីអង្គការលេខ និងនិមិត្តសញ្ញារបស់អង្គភាពសវនកម្មផ្ទៃក្នុង

* * * *

អង្គការលេខរបស់អង្គភាពសវនកម្មផ្ទៃក្នុង

និមិត្តសញ្ញារបស់អង្គភាពសវនកម្មផ្ទៃក្នុង

អត្ថន័យ÷

និមិត្តសញ្ញារបស់អង្គភាពសវនកម្មផ្ទៃក្នុង មានអត្ថន័យដូចខាងក្រោម÷

- **រូបហត្ថព្រះរាជាណាចក្រកម្ពុជា÷** តំណាងឱ្យឧត្តការតាមដាន និងត្រួតពិនិត្យរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ប្រកបដោយជំនាញវិជ្ជាជីវៈ ក្រមសីលធម៌ ឯករាជ្យភាព សុចរិតភាព និងការទទួលខុសត្រូវ
- **ម៉ឺងនៃត្រីកោណ÷** តំណាងឱ្យយុទ្ធសាស្ត្រទាំងពារបស់អង្គភាពសវនកម្មផ្ទៃក្នុង ដែលផ្តោតលើគុណភាព គុណតម្លៃ និងការលុបបំបាត់ភាពអសកម្ម។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:២៣៤:អនក្រ-បក

អនុក្រឹត្យ
ស្តីពី
ការកែសម្រួលរចនាសម្ព័ន្ធ ក្លនាធី និងភារកិច្ចរបស់អគ្គភាពចំណុះ ក្រសួងមុខងារសាធារណៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦២១/៤៤៩ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការដ្ឋាប្រធានស្ថាប័ន
- បានឃើញអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ ស្តីពីក្របខ័ណ្ឌមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច
- បានឃើញអនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន និងអនុគណៈកម្មាធិការរបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះកំណត់ពីការកែសម្រួល និងបំពេញបន្ថែម រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់អង្គភាពចំណុះក្រសួងមុខងារសាធារណៈ។

ជំពូកទី២

អគ្គនាយកដ្ឋានកិច្ចការទូទៅ

មាត្រា ២.-

អគ្គនាយកដ្ឋានកិច្ចការទូទៅមានតួនាទី និងភារកិច្ចធ្វើជាសេនាធិការឱ្យក្រសួងមុខងារសាធារណៈក្នុងការគ្រប់គ្រងកិច្ចការទូទៅ ការងារនីតិកម្ម ទំនាក់ទំនងសាធារណៈ និងកិច្ចសហប្រតិបត្តិការជាមួយអន្តរជាតិ និងអាស៊ាន និងបំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។

អគ្គនាយកដ្ឋានកិច្ចការទូទៅដឹកនាំដោយអគ្គនាយកមួយរូបនិងអគ្គនាយករងមួយចំនួនជាជំនួយការ តាមការចាំបាច់ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

មាត្រា ៣.-

អគ្គនាយកដ្ឋានកិច្ចការទូទៅ មានរចនាសម្ព័ន្ធដូចខាងក្រោម៖

១- នាយកដ្ឋាននីតិកម្ម

២- នាយកដ្ឋានទំនាក់ទំនងសាធារណៈ

៣-នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ

៤- មជ្ឈមណ្ឌលធនធានអាស៊ានកម្ពុជា ដែលមានថ្នាក់ស្មើនឹងនាយកដ្ឋាន។

នាយកដ្ឋាន និងមជ្ឈមណ្ឌល ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គការលេខអគ្គនាយកដ្ឋានកិច្ចការទូទៅនៃក្រសួងមុខងារសាធារណៈ ជាឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ។

មាត្រា ៤.-

នាយកដ្ឋាននីតិកម្ម មានភារកិច្ចដូចខាងក្រោម ៖

- សិក្សា ស្រាវជ្រាវ កសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធវិស័យមុខងារសាធារណៈ
- ចូលរួមពិនិត្យ និងផ្តល់យោបល់លើការរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ ដែលផ្តួចផ្តើមដោយក្រសួង ស្ថាប័នផ្សេងទៀត
- សហការជាមួយអង្គភាពចំណុះក្រសួងមុខងារសាធារណៈ ជាមួយអង្គការជាតិ និងអន្តរជាតិ ក្នុងការរៀបចំប្រតិទិននៃការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ
- ប្រមូលផ្តុំ ចងក្រង បោះពុម្ពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ
- ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក។

មាត្រា ៥.-

នាយកដ្ឋានទំនាក់ទំនងសាធារណៈ មានភារកិច្ចដូចខាងក្រោម ៖

- សហការជាមួយក្រសួង ស្ថាប័ន និងបណ្តាញព័ត៌មាននានានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីប្រមូលទិន្នន័យ ព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ សម្រាប់ផ្សព្វផ្សាយ ផ្តល់ព័ត៌មាន ឆ្លើយបំភ្លឺដល់ស្ថាប័នពាក់ព័ន្ធ និងសាធារណជន

- ដឹកនាំ គ្រប់គ្រងខ្លឹមសារ និងមធ្យោបាយនៃការផ្សព្វផ្សាយព័ត៌មានផ្លូវការរបស់ក្រសួង
- រៀបចំសន្និសីទសារព័ត៌មាន សេចក្តីថ្លែងការណ៍ និងសេចក្តីជូនដំណឹងផ្សេងៗ ដែលត្រូវផ្សព្វផ្សាយតាមកាសែត ទូរទស្សន៍ គេហទំព័រ និងប្រព័ន្ធបណ្តាញព័ត៌មានសង្គម
- រៀបចំ និងកសាងឯកសារសម្រាប់ផ្សព្វផ្សាយព័ត៌មានពីសមិទ្ធផលការងាររបស់ក្រសួង និងមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត រួមទាំងសកម្មភាពការងាររបស់រដ្ឋមន្ត្រី ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងមុខងារសាធារណៈ
- ស្រាវជ្រាវ និងវិភាគព័ត៌មានដែលផ្សព្វផ្សាយតាមគេហទំព័រ និងតាមបណ្តាញព័ត៌មានសង្គមនានា ដើម្បីប្រើប្រាស់ជាមូលដ្ឋានបម្រើដល់ការដឹកនាំ និងទប់ស្កាត់ព័ត៌មានក្លែងក្លាយឱ្យបានទាន់ពេលវេលា
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក។

មាត្រា ៦.-

នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ មានភារកិច្ចដូចខាងក្រោម ៖

- សហប្រតិបត្តិការជាអន្តរជាតិ ក្នុងកិច្ចការមុខងារសាធារណៈជាមួយប្រទេសនានាក្នុងតំបន់ និងពិភពលោក
- ទំនាក់ទំនងជាមួយបណ្តាប្រទេសតាមរយៈស្ថានទូត និងជាមួយអង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ក្នុងវិស័យមុខងារសាធារណៈ
- រៀបចំផែនការយុទ្ធសាស្ត្រ និងថវិកាសម្រាប់កិច្ចការសហប្រតិបត្តិការអន្តរជាតិ ក្នុងវិស័យមុខងារសាធារណៈ
- រៀបចំឯកសារនានាជាអាទិ៍ អនុស្សរណៈនៃការយោគយល់គ្នា ពិធីសារ កិច្ចព្រមព្រៀង លិខិតស្នាមនានា ដែលពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យមុខងារសាធារណៈ
- រៀបចំឯកសារនានា ដែលទាក់ទងនឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសក្រៅពីអាស៊ាន មានជាអាទិ៍ ការបណ្តុះបណ្តាល ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិល ការផ្លាស់ប្តូរបទពិសោធន៍ កិច្ចប្រជុំ និងសកម្មភាពនានាពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ
- រៀបចំឯកសារ និងជំនួយស្មារតីសម្រាប់កិច្ចប្រជុំសំខាន់ៗរបស់ថ្នាក់ដឹកនាំជាមួយភាគីពាក់ព័ន្ធក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងកម្រិតតំបន់ និងពិភពលោក

- រៀបចំបែបបទពិធីការ ឯកសារធ្វើដំណើរ និងទម្រង់បែបបទនានាសម្រាប់បេសកកម្ម នៅបរទេស របស់ថ្នាក់ដឹកនាំ និងគណៈប្រតិភូរបស់ក្រសួងមុខងារសាធារណៈ
- រៀបចំ និងសម្របសម្រួលគណៈប្រតិភូអន្តរជាតិចូលរួមក្នុងសន្និសីទ កិច្ចប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗពាក់ព័ន្ធវិស័យមុខងារសាធារណៈ ដែលប្រព្រឹត្តទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ត្រួតពិនិត្យការអនុវត្តផែនការសកម្មភាព និងគម្រោងនានាពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យមុខងារសាធារណៈ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក។

មាត្រា ៧.-

មជ្ឈមណ្ឌលធនធានអាស៊ានកម្ពុជា មានភារកិច្ចដូចខាងក្រោម ៖

- សហប្រតិបត្តិការជាមួយប្រទេសសមាជិកអាស៊ានលើកិច្ចការមុខងារសាធារណៈ
- គ្រប់គ្រងព័ត៌មាន និងឯកសារដែលទាក់ទងនឹងវិស័យមុខងារសាធារណៈអាស៊ាន ព្រមទាំងផ្លាស់ប្តូរ និងផ្សព្វផ្សាយព័ត៌មានជាមួយមជ្ឈមណ្ឌលធនធានអាស៊ាននៃប្រទេសសមាជិកអាស៊ាន
- រៀបចំឯកសារពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអាស៊ានផ្នែកមុខងារសាធារណៈមានដូចជាអាទិ៍ ការបណ្តុះបណ្តាល ការផ្លាស់ប្តូរបទពិសោធន៍ កិច្ចប្រជុំ និងសកម្មភាពដទៃទៀតផ្នែកមុខងារសាធារណៈ ដើម្បីអភិវឌ្ឍន៍សមត្ថភាពមន្ត្រីរាជការស៊ីវិល
- សហការជាមួយលេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការអាស៊ានលើវិស័យមុខងារសាធារណៈ
- រៀបចំនិងសម្របសម្រួលកិច្ចប្រជុំសហប្រតិបត្តិការផ្នែកមុខងារសាធារណៈរបស់អាស៊ាន និងរបស់អាស៊ានបូកបី : ចិន ជប៉ុន កូរ៉េ និងកិច្ចប្រជុំអន្តរជាតិដទៃទៀត
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក។

ជំពូកទី៣
អគ្គនាយកដ្ឋានផែនការ ស្ថិតិ និងគ្រប់គ្រងមន្ត្រីរាជការ តាមប្រព័ន្ធព័ត៌មានវិទ្យា

មាត្រា ៨.-

អគ្គនាយកដ្ឋានផែនការ ស្ថិតិ និងគ្រប់គ្រងមន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យា មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ដឹកនាំកសាងផែនការក្របខ័ណ្ឌ និងគ្រប់គ្រងស្ថិតិមន្ត្រីរាជការ បុគ្គលិកបម្រើការងាររដ្ឋ តាមប្រព័ន្ធនិយោជន៍ (បុគ្គលិកជាប់កិច្ចសន្យា បុគ្គលិកអណ្តែត។ល។) នៅទូទាំងប្រទេស
- ដឹកនាំ អភិវឌ្ឍ និងធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងមន្ត្រីរាជការ បុគ្គលិកបម្រើការងាររដ្ឋតាមប្រព័ន្ធនិយោជន៍នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ដឹកនាំ អភិវឌ្ឍ និងធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការទូទាត់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់មន្ត្រីរាជការ និងបុគ្គលិកបម្រើការងារដ្ឋតាមប្រព័ន្ធនិយោជន៍
- ហ្វឹកហ្វឺន និងបណ្តុះបណ្តាលមន្ត្រីជំនាញព័ត៌មានវិទ្យាបម្រើឱ្យវិស័យមុខងារសាធារណៈ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។

អគ្គនាយកដ្ឋានផែនការ ស្ថិតិ និងគ្រប់គ្រងមន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យា ដឹកនាំដោយអគ្គនាយកមួយរូប និងអគ្គនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

មាត្រា ៩.-

អគ្គនាយកដ្ឋានផែនការ ស្ថិតិ និងគ្រប់គ្រងមន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យា មានរចនាសម្ព័ន្ធដូចខាងក្រោម ៖

១- នាយកដ្ឋានផែនការ និងគ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការ

២- នាយកដ្ឋានគ្រប់គ្រងឯកសារ និងស្ថិតិមន្ត្រីរាជការ

៣- នាយកដ្ឋានគ្រប់គ្រង និងអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា

៤- នាយកដ្ឋានគ្រប់គ្រងបៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗតាមប្រព័ន្ធព័ត៌មានវិទ្យា

៥- មជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកវិទ្យា ព័ត៌មាន និងគមនាគមន៍ ដែលមានថ្នាក់ស្មើនឹងនាយកដ្ឋាន។

នាយកដ្ឋាននិងមជ្ឈមណ្ឌលដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គការរៀបរបស់អគ្គនាយកដ្ឋានផែនការ ស្ថិតិ និងគ្រប់គ្រងមន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យាជាឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ។

មាត្រា ១០.-

នាយកដ្ឋានផែនការ និងគ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការ មានភារកិច្ចដូចខាងក្រោម ៖

- សិក្សាពីតម្រូវការក្របខ័ណ្ឌ និងកសាងផែនការរយៈពេលខ្លី មធ្យម និងវែងសម្រាប់ការជ្រើសរើសមន្ត្រីរាជការចូលបម្រើការងារក្នុងក្របខ័ណ្ឌរដ្ឋ ដោយផ្អែកលើការវិភាគ

រចនាសម្ព័ន្ធ ទំហំការងារ ការវិភាគមុខងារ និងដោយផ្អែកលើលទ្ធភាពសេដ្ឋកិច្ច ស្ថានភាពកូមិសាស្ត្រ និងប្រជាសាស្ត្រ

- កសាងផែនការសម្រាប់ការជ្រើសរើសបុគ្គលិកចូលបម្រើការងាររដ្ឋតាមប្រព័ន្ធនិយោជន៍
- សិក្សាពីតម្រូវការនៃការប្រើប្រាស់មន្ត្រីរាជការ និងបុគ្គលិកបម្រើការងាររដ្ឋតាមប្រព័ន្ធនិយោជន៍របស់ក្រសួង ស្ថាប័ន សម្រាប់រយៈពេលខ្លី មធ្យម និងវែង នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ពិនិត្យ និងផ្តល់យោបល់លើផែនការក្របខ័ណ្ឌរបស់ក្រសួង ស្ថាប័ននីមួយៗ
- បង្កើតតារាងព័ត៌មានឯកភាពសម្រាប់ការគ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការ និងបុគ្គលិកបម្រើការងាររដ្ឋតាមប្រព័ន្ធនិយោជន៍ នៅតាមក្រសួង ស្ថាប័ននានា នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បំពេញការកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក។

មាត្រា ១១.-

នាយកដ្ឋានគ្រប់គ្រងឯកសារ និងស្ថិតិមន្ត្រីរាជការ មានភារកិច្ចដូចខាងក្រោម ៖

- ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ស្រង់បញ្ចូល និងធ្វើបច្ចុប្បន្នភាពព័ត៌មានមន្ត្រីរាជការក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ
- រៀបចំ ពិនិត្យកែសម្រួល និងរក្សាទុកសណាកប័ត្រមន្ត្រីរាជការ ក្នុងបណ្ណសារដ្ឋានតាមប្រព័ន្ធព័ត៌មានវិទ្យា
- រៀបចំបោះពុម្ពប័ណ្ណមន្ត្រីរាជការ និងសណាកប័ត្រព័ត៌មានមន្ត្រីរាជការចូលនិវត្តន៍
- រៀបចំរបាយការណ៍ និងចងក្រងឯកសារស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ប្រចាំឆ្នាំ
- កសាងរបាយការណ៍ផ្លូវការស្តីពីស្ថានភាពរបស់មន្ត្រីរាជការ និងបុគ្គលិកបម្រើការងាររដ្ឋតាមប្រព័ន្ធនិយោជន៍ នៅទូទាំងប្រទេស
- បំពេញការកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក។

មាត្រា ១២.-

នាយកដ្ឋានគ្រប់គ្រង និងអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា មានភារកិច្ចដូចខាងក្រោម ៖

- កសាងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពដើម្បីជំរុញការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ សម្រាប់ការគ្រប់គ្រងមន្ត្រីរាជការទូទាំងប្រទេស
- ស្រាវជ្រាវ បង្កើតកម្មវិធី និងគម្រោងនានា ដើម្បីអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ

- គ្រប់គ្រង និងរក្សាសុវត្ថិភាព ទិន្នន័យមន្ត្រីរាជការ មជ្ឈមណ្ឌលទិន្នន័យ ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍របស់ក្រសួងមុខងារសាធារណៈ ដើម្បីធានាប្រសិទ្ធភាពនៃប្រព័ន្ធតភ្ជាប់ជាមួយក្រសួង ស្ថាប័ន អង្គភាព នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- សហការ គាំទ្រ សម្របសម្រួល និងផ្តល់យោបល់ផ្នែកបច្ចេកទេសដល់ក្រសួង ស្ថាប័ននានា និងអគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាពនានាចំណុះក្រសួងមុខងារសាធារណៈ លើការងារពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍
- គ្រប់គ្រង និងអភិវឌ្ឍគេហទំព័រ និងបណ្តាញសារអេឡិចត្រូនិករបស់ក្រសួងមុខងារសាធារណៈ
- សហប្រតិបត្តិការក្នុងការអភិវឌ្ឍវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ សម្រាប់ក្រសួងមុខងារសាធារណៈ
- បំពេញការកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក។

មាត្រា ១៣.-

នាយកដ្ឋានគ្រប់គ្រងបៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗតាមប្រព័ន្ធព័ត៌មានវិទ្យា មានការកិច្ចដូចខាងក្រោម ៖

- ដំរុញការរៀបចំ តារាងទូទាត់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗតាមប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ដើម្បីធានាដល់ការបើកផ្តល់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗជូនមន្ត្រីរាជការ និងបុគ្គលិកបម្រើការងាររដ្ឋតាមប្រព័ន្ធនិយោជន៍ ឱ្យបានត្រឹមត្រូវ និងទៀងទាត់
- ធ្វើបច្ចុប្បន្នភាពស្ថានភាពមន្ត្រីរាជការ និងបុគ្គលិកបម្រើការងាររដ្ឋតាមប្រព័ន្ធនិយោជន៍ក្នុងតារាងទូទាត់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ
- ពិនិត្យ បញ្ចូលទិន្នន័យ ផ្ទៀងផ្ទាត់ទិន្នន័យ និងសម្រេចលើតារាងទូទាត់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់មន្ត្រីរាជការ និងបុគ្គលិកបម្រើការងាររដ្ឋតាមប្រព័ន្ធនិយោជន៍
- ជូនដំណឹងពីទឹកប្រាក់ក្នុងអាណត្តិបើកប្រាក់ និងរៀបចំតារាងទូទាត់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់ថ្នាក់ដឹកនាំចុះហត្ថលេខា និងផ្តល់ជូនសាមីក្រសួង ស្ថាប័ន និងរាជធានី ខេត្ត
- គ្រប់គ្រង និងបំលែងតារាងទូទាត់បៀវត្ស ប្រាក់ឧបត្ថម្ភផ្សេងៗ និងអាណត្តិបើកប្រាក់ជាទម្រង់អេឡិចត្រូនិក
- បំពេញការកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក។

មាត្រា ១៤.-

មជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ មានភារកិច្ចដូចខាងក្រោម ៖

- រៀបចំកម្មវិធី និងផែនការបណ្តុះបណ្តាល រយៈពេលខ្លី មធ្យម និងវែង ដល់មន្ត្រីរាជការដែលបំពេញការងារផ្នែកបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍
- រៀបចំវគ្គហ្វឹកហ្វឺន បំពាក់បំប៉នការប្រើប្រាស់កម្មវិធី និងគម្រោងនានា ដែលគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ ការទូទាត់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗតាមប្រព័ន្ធព័ត៌មានវិទ្យា
- សិក្សា ស្រាវជ្រាវពីបច្ចេកវិទ្យា និងនវានុវត្តន៍របស់បណ្តាប្រទេសជឿនលឿនខាងការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការតាមព័ត៌មានវិទ្យា ដើម្បីធ្វើជាមូលដ្ឋានសម្រាប់វគ្គបណ្តុះបណ្តាលវគ្គហ្វឹកហ្វឺនទាំងឡាយដែលរៀបចំដោយមជ្ឈមណ្ឌល
- សហប្រតិបត្តិការ និងផ្លាស់ប្តូរបទពិសោធន៍ជាមួយផ្នែកជំនាញបច្ចេកវិទ្យា និងនវានុវត្តន៍របស់ប្រទេសនានាក្នុងតំបន់ និងលើសកលលោក សម្រាប់បម្រើការគ្រប់គ្រងវិស័យមុខងារសាធារណៈ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក។

ជំពូកទី៤

អគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ

មាត្រា ១៥.-

អគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ មានតួនាទី និងភារកិច្ចដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការជ្រើសរើសមន្ត្រីរាជការ និងបុគ្គលិក ការតាំងស៊ប់ ការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ ការតែងតាំង ការផ្ទេរ ការផ្លាស់ប្តូរ ការបញ្ចេញពីក្របខ័ណ្ឌ ការដាក់ឱ្យចូលនិវត្តន៍ និងការកំណត់របបគាំពារសុខុមាលភាព សម្រាប់មន្ត្រីរាជការ និវត្តន៍ជន និងមន្ត្រីរាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈ និងបំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។

អគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ ដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

មាត្រា ១៦.-

អគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ មានរចនាសម្ព័ន្ធដូចខាងក្រោម ៖

១- នាយកដ្ឋានជ្រើសរើសមន្ត្រីរាជការ និងបុគ្គលិកបម្រើការងាររដ្ឋតាមប្រព័ន្ធនិយោជន៍

២- នាយកដ្ឋានតាំងស៊ប់ ដំឡើងឋានន្តរស័ក្តិ និងថ្នាក់

៣- នាយកដ្ឋានតែងតាំង ផ្ទេរ ផ្លាស់ប្តូរ បញ្ចេញពីក្របខ័ណ្ឌ និងចូលនិវត្តន៍

៤- នាយកដ្ឋានគាំពារសុខុមាលភាពមន្ត្រីរាជការ។

នាយកដ្ឋាន ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គការលេខអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ នៃក្រសួងមុខងារសាធារណៈ ជាឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យនេះ។

មាត្រា ១៧.-

នាយកដ្ឋានជ្រើសរើសមន្ត្រីរាជការ និងបុគ្គលិកបម្រើការងាររដ្ឋតាមប្រព័ន្ធនិយោជន៍ មានភារកិច្ចដូចខាងក្រោម ៖

- កសាងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការជ្រើសរើសមន្ត្រីចូលក្នុងក្របខ័ណ្ឌរដ្ឋ និងការជ្រើសរើសបុគ្គលិកបម្រើការងាររដ្ឋតាមប្រព័ន្ធនិយោជន៍
- រៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់ការប្រឡងជ្រើសរើសមន្ត្រីរាជការ និងបុគ្គលិកបម្រើការងាររដ្ឋតាមប្រព័ន្ធនិយោជន៍
- កំណត់គោលការណ៍ បែបបទ និងនីតិវិធីសម្រាប់ត្រួតពិនិត្យតម្លាភាព និងគណនេយ្យភាព ដើម្បីជានាគុណាធិបតេយ្យ ក្នុងដំណើរការប្រឡងជ្រើសរើសមន្ត្រីរាជការ និងបុគ្គលិកបម្រើការងាររដ្ឋតាមប្រព័ន្ធនិយោជន៍ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ពិនិត្យ សម្រេចសុពលភាពលើលទ្ធផលនៃការប្រឡង និងផ្តល់ទិដ្ឋាការលើបញ្ជីបេក្ខជនប្រឡងជាប់ និងផ្តល់សញ្ញាបត្រដល់មន្ត្រីថ្មីដើម្បីធ្វើកម្មសិក្សា
- ពិនិត្យ និងផ្តល់ទិដ្ឋាការដល់បុគ្គលិកបម្រើការងាររដ្ឋតាមប្រព័ន្ធនិយោជន៍ដែលត្រូវបានជ្រើសរើស
- គ្រប់គ្រងការរក្សាទុករាល់សំណុំឯកសារពាក់ព័ន្ធដល់ការប្រឡងជ្រើសរើសមន្ត្រីរាជការ និងបុគ្គលិកបម្រើការងាររដ្ឋតាមប្រព័ន្ធនិយោជន៍
- បំពេញការកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក។

មាត្រា ១៨.-

នាយកដ្ឋានតាំងស៊ប់ ដំឡើងឋានន្តរស័ក្តិ និងថ្នាក់ មានភារកិច្ចដូចខាងក្រោម ៖

- សិក្សា ស្រាវជ្រាវដើម្បីកំណត់គោលការណ៍ លក្ខខណ្ឌ សម្រាប់ការតាំងស៊ប់ ការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ ដើម្បីធានាគុណភាពរបស់មន្ត្រីរាជការដោយផ្អែកលើការវិនិច្ឆ័យតាមបែបគុណាធិបតេយ្យ
- រៀបចំបែបបទ និងនីតិវិធីនៃការតាំងស៊ប់ ការដំឡើងឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការ
- ពិនិត្យ និងផ្តល់យោបល់លើសំណើតាំងស៊ប់ ដំឡើងឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការ
- រៀបចំសេចក្តីព្រាង ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសស្តីពីការតាំងស៊ប់ ការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ ស្របតាមលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗ
- បំពេញការកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក។

មាត្រា ១៩.-

នាយកដ្ឋានតែងតាំង ផ្ទេរ ផ្លាស់ប្តូរ បញ្ចេញពីក្របខ័ណ្ឌ និងចូលនិវត្តន៍ មានភារកិច្ចដូចខាងក្រោម ៖

- សិក្សា ស្រាវជ្រាវ រៀបចំគោលការណ៍ និងនីតិវិធី ដែលទាក់ទងនឹងការតែងតាំង ការផ្ទេរ ការផ្លាស់ប្តូរ ការបញ្ចេញពីក្របខ័ណ្ឌ និងការដាក់ឱ្យចូលនិវត្តន៍ មន្ត្រីរាជការ
- ពិនិត្យ ផ្ទៀងផ្ទាត់ ដើម្បីផ្តល់ទិដ្ឋាការ និងបញ្ជាក់នីត្យានុកូលភាព នៃការសុំតែងតាំង ការផ្ទេរ ការផ្លាស់ប្តូរ ការបញ្ចប់មុខតំណែង
- ពិនិត្យ ផ្ទៀងផ្ទាត់ ការផ្ទេរ ការផ្លាស់ប្តូរ ការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ការដាក់ឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ការបញ្ចេញពីក្របខ័ណ្ឌ ការដាក់វិន័យ ការលុបឈ្មោះឬការបញ្ឈប់ពីការងារជាអ្នករាជការ ការដាក់ឱ្យចូលនិវត្តន៍ និងការបាត់បង់សម្បទាវិជ្ជាជីវៈ
- បំពេញការកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក។

មាត្រា ២០.-

នាយកដ្ឋានគាំពារសុខុមាលភាពមន្ត្រីរាជការ មានភារកិច្ចដូចខាងក្រោម ៖

- ស្រាវជ្រាវ កំណត់គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តដើម្បីកសាងប្រព័ន្ធគាំពារសុខុមាលភាពសម្រាប់មន្ត្រីរាជការ

- កសាងរបបកំណត់ ការបំពេញការងារ ការឈប់សម្រាក លំហែមាតុ/បិតុភាព ការគាំពារសុខុមាលភាព (ឈឺ ហានិភ័យការងារ គ្រោះថ្នាក់ការងារ ការបាត់បង់សម្បទាវិជ្ជាជីវៈ។ល។) និងការចូលនិវត្តន៍
- កសាងរបបកំណត់អត្ថប្រយោជន៍សម្រាប់មន្ត្រីរាជការពេលបំពេញការងារ ពេលបាត់បង់ការងារ គ្រោះថ្នាក់ការងារ បាត់បង់សម្បទាវិជ្ជាជីវៈ ពេលចូលនិវត្តន៍ និងក្រោយពេលចូលនិវត្តន៍
- សហការ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីកសាងយន្តការអភិបាលកិច្ចក្នុងការអនុវត្តកម្មវិធីគាំពារសុខុមាលភាពសម្រាប់មន្ត្រីរាជការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក។

ជំពូកទី៥
អគ្គាធិការដ្ឋាន

មាត្រា ២១.-

អគ្គាធិការដ្ឋាននៃក្រសួងមុខងារសាធារណៈ មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ធ្វើជាសេនាធិការឱ្យក្រសួងមុខងារសាធារណៈ ក្នុងកិច្ចការអធិការកិច្ចលើវិស័យមុខងារសាធារណៈ
- ធ្វើជាលេខាធិការដ្ឋានឱ្យគណៈកម្មាធិការសម្រុះសម្រួលវិវាទមុខងារសាធារណៈ
- បំពេញភារកិច្ចផ្សេងទៀត តាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។

អគ្គាធិការដ្ឋាន ដឹកនាំដោយអគ្គាធិការមួយរូប និងមានអគ្គាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

មាត្រា ២២.-

អគ្គាធិការដ្ឋានមានរចនាសម្ព័ន្ធ ដូចខាងក្រោម ៖

១- នាយកដ្ឋានរដ្ឋបាល

២- នាយកដ្ឋានអធិការកិច្ចក្រសួង ស្ថាប័នថ្នាក់ជាតិ

៣- នាយកដ្ឋានអធិការកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិ

៤- នាយកដ្ឋានដោះស្រាយវិវាទមុខងារសាធារណៈ។

នាយកដ្ឋាននីមួយៗដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គភាពលេខាធិការដ្ឋាននៃក្រសួងមុខងារសាធារណៈ ជាឧបសម្ព័ន្ធទី៤ នៃអនុក្រឹត្យនេះ។

មាត្រា ២៣.-

នាយកដ្ឋានរដ្ឋបាល មានភារកិច្ចដូចខាងក្រោម ៖

- សិក្សា ស្រាវជ្រាវ កសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងអធិការកិច្ចមុខងារសាធារណៈ
- សិក្សា ស្រាវជ្រាវ រៀបចំទិន្នន័យ កសាងកម្មវិធី និងផែនការសកម្មភាពតាមរយៈពេលកំណត់របស់អគ្គាធិការដ្ឋាន
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ការអនុវត្តការងាររបស់នាយកដ្ឋានចំណុះអគ្គាធិការដ្ឋាន
- សហការ និងសម្របសម្រួលការងារអធិការកិច្ចជាមួយក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីលទ្ធផលអធិការកិច្ចមុខងារសាធារណៈ
- គ្រប់គ្រងចរាចរឯកសាររដ្ឋបាល លិខិតស្នាម របស់អគ្គាធិការដ្ឋាន
- បំពេញការកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គាធិការ។

មាត្រា ២៤.-

នាយកដ្ឋានអធិការកិច្ចក្រសួង ស្ថាប័នថ្នាក់ជាតិ មានភារកិច្ចដូចខាងក្រោម ៖

- ធ្វើអធិការកិច្ចពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការ និងបុគ្គលិកបម្រើការងាររដ្ឋតាមប្រព័ន្ធនិយោជន៍នៃក្រសួង ស្ថាប័នថ្នាក់ជាតិ
- ធ្វើអធិការកិច្ចពាក់ព័ន្ធនឹងការជ្រើសរើស ការប្រើប្រាស់ក្របខ័ណ្ឌមន្ត្រីរាជការ និងបុគ្គលិកបម្រើការងាររដ្ឋតាមប្រព័ន្ធនិយោជន៍នៃក្រសួង ស្ថាប័នថ្នាក់ជាតិ
- ធ្វើអធិការកិច្ចពាក់ព័ន្ធនឹងការតែងតាំង ការប្រគល់ភារកិច្ច ការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ការដាក់វិន័យ ការបញ្ចប់ភារកិច្ច និងការចូលនិវត្តន៍ មន្ត្រីរាជការនៃក្រសួង ស្ថាប័នថ្នាក់ជាតិ
- ធ្វើអធិការកិច្ចលើការកសាង និងអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការនៃក្រសួង ស្ថាប័នថ្នាក់ជាតិ
- ធ្វើអធិការកិច្ចលើបញ្ហាដទៃទៀតដែលពាក់ព័ន្ធដល់វិស័យមុខងារសាធារណៈ
- បំពេញការកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គាធិការ។

មាត្រា ២៥.-

នាយកដ្ឋានអធិការកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិ មានភារកិច្ចដូចខាងក្រោម ៖

- ធ្វើអធិការកិច្ចពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការ និងបុគ្គលិកបម្រើការងាររដ្ឋតាមប្រព័ន្ធនិយោជន៍នៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- ធ្វើអធិការកិច្ចពាក់ព័ន្ធនឹងការជ្រើសរើស ការប្រើប្រាស់ក្របខ័ណ្ឌមន្ត្រីរាជការ និងបុគ្គលិកបម្រើការងាររដ្ឋតាមប្រព័ន្ធនិយោជន៍នៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- ធ្វើអធិការកិច្ចពាក់ព័ន្ធនឹងការតែងតាំង ការប្រគល់ភារកិច្ច ការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ការដាក់វិន័យ ការបញ្ចប់ភារកិច្ច និងការចូលនិវត្តន៍មន្ត្រីរាជការ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- ធ្វើអធិការកិច្ចលើការកសាង និងអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការនៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- ធ្វើអធិការកិច្ចលើបញ្ហាដទៃទៀតដែលពាក់ព័ន្ធដល់វិស័យមុខងារសាធារណៈនៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គាធិការ។

មាត្រា ២៦.-

នាយកដ្ឋានដោះស្រាយវិវាទមុខងារសាធារណៈ មានភារកិច្ចដូចខាងក្រោម ៖

- សិក្សា ស្រាវជ្រាវ កសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិវាទមុខងារសាធារណៈ
- ទទួលពាក្យបណ្តឹង អង្កេតស្រាវជ្រាវ សម្រុះសម្រួល និងដោះស្រាយវិវាទមុខងារសាធារណៈ
- កសាងសំណុំឯកសារសម្រាប់ការដោះស្រាយវិវាទមុខងារសាធារណៈដែលជាសមត្ថកិច្ចរបស់គណៈកម្មាធិការសម្រុះសម្រួលវិវាទមុខងារសាធារណៈ
- តាមដានការអនុវត្តសេចក្តីសម្រេច លើការដោះស្រាយវិវាទមុខងារសាធារណៈ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គាធិការ។

ជំពូកទី៦

អវសានប្បញ្ញត្តិ

មាត្រា ២៧.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ២៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ទុតិយកើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០២១

ក្រុមប្រឹក្សារដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា
រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

ង្វៀ សុខា

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី ១

អនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុងខែ ១០ ខែ ៧ ឆ្នាំ ២០២១

អង្គភាពរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករ នៃក្រសួងមុខងារសាធារណៈ

ឧបសម្ព័ន្ធទី២

អនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០២១

អង្គការរបស់អគ្គនាយកដ្ឋានវៃឆ្លាស ស្តីពី និយ្យតកម្មក្នុងវិស័យព័ត៌មានវិទ្យា

នៃក្រសួងមុខងារសាធារណៈ

ឧបសម្ព័ន្ធទី៣

អនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២១

អង្គភាពរបស់អគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ នៃក្រសួងមុខងារសាធារណៈ

ឧបសម្ព័ន្ធទី៤

អនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែវិសាខ ឆ្នាំ២០២១

អង្គភាពរបស់អគ្គធិការដ្ឋាន នៃក្រសួងមុខងារសាធារណៈ:

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៣៤.អនក្រ បក

អនុក្រឹត្យ

ស្តីពី

ការផ្តេរឥណទានទឋវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃ សុក្រ ១១កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៧ អនក្រ.បក ចុះថ្ងៃ អង្គារ ១៥កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២០ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

មាត្រា១._

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ២១ លានរៀល (ម្ភៃមួយលានរៀលគត់) ពីជំពូក ៦០ (ការទិញ) មកបំពេញក្នុងជំពូក ៦៣ (ពន្ធ និងអាករ) ជូនមន្ទីរបៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីរាជធានីភ្នំពេញ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១។

មាត្រា២._

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់បន្តនិរន្តរភាពការងារអាទិភាពនិងដំណើរការ រដ្ឋបាល ក្នុងឆ្នាំ ២០២១។

មាត្រា៣._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៦កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមមហាគ្រុលេខា

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:.៣៦.ន.អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការផ្ទេរការកិច្ច និងតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៨/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ផ្ទេរភារកិច្ចមន្ត្រីរាជការចំនួន ០៣រូប នៅក្នុងខេត្តកំពង់ធំ ដូចមានរាយនាមខាងក្រោម:

១-លោក **ឡូច គីសីង**	ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៦ ពីអភិបាលស្រុកសណ្តាន់ ឲ្យទៅកាន់មុខតំណែងជា**អភិបាលស្រុកសន្ទុក**
២-លោក **អ៊ុត ឥណ្ណារ៉ា**	ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ១ ពីអភិបាលស្រុកប្រាសាទសំបូរ ឲ្យទៅកាន់មុខតំណែងជា**អភិបាលស្រុកសណ្តាន់**

៣-លោក **ណែត សារី** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ១ ពីអភិបាលស្រុកស្ទោង ឲ្យទៅបម្រើការងារនៅរដ្ឋបាលខេត្តកំពង់ធំ។

មាត្រា ២ : តែងតាំងមន្ត្រីរាជការចំនួន ០២រូប ឲ្យកាន់មុខតំណែងជាអភិបាលស្រុក នៃខេត្តកំពង់ធំ ដូចមានរាយនាមខាងក្រោម:

១-លោក **សាយ គីមឡុម** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៨ ឲ្យកាន់មុខតំណែងជាអភិបាលស្រុកស្ទោង

២-លោក **ឆង់ គីមតុល** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ២ ឲ្យកាន់មុខតំណែងជាអភិបាលស្រុកប្រាសាទសំបូរ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ និងមាត្រា២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ស្ដីក្រ ១៣ កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅភ្នំពេញ ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០២១

ទីកន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

តាមនាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..ណ.ប៧០.អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៨/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ផ្ទេរភារកិច្ចលោក **ឃឹម សំណាង** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៥ ពីអភិបាលស្រុកភ្នំស្រុក ឲ្យទៅកាន់មុខតំណែងជាអភិបាលស្រុកអូរជ្រៅ នៃខេត្តបន្ទាយមានជ័យ។

មាត្រា ២ : តែងតាំងមន្ត្រីរាជការចំនួន ០២រូប ឲ្យកាន់មុខតំណែងជាអភិបាលស្រុក នៃខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម:

១-លោក **ជុំ បុត្រ**	ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៨ ឲ្យកាន់មុខតំណែងជាអភិបាលស្រុកភ្នំស្រុក
២-លោក **ស្វាយ ជា**	ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៨ ឲ្យកាន់មុខតំណែងជាអភិបាលស្រុកម៉ាឡៃ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា ១ និងមាត្រា ២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ខែកត្តិក ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ✓

ទីន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ឧទ្ធកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ឧទ្ធកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- កាដកិច្ច
- ឯកសារ-កាលប្បវត្តិ

តាមការអញ្ជើញ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:ព.ស.២៥៦៤.អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការដាក់មន្ត្រីពន្ធនាគារឲ្យចូលនិវត្តន៍

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រងដំណើរការ នៃការដាក់មន្ត្រីរាជការស៊ីវិលឲ្យចូលនិវត្តន៍តាមអាយុតាមប្រព័ន្ធព័ត៌មានវិទ្យា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ .-

ដាក់មន្ត្រីពន្ធនាគារចំនួន ០៦រូប ឲ្យចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិវរអគ្គានុរក្ស នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ :

១- លោក **ជោ ទណ្ណា** អត្តលេខ ០៤៧០ វរអគ្គានុរក្សថ្នាក់លេខ១

២- លោក **ចាន់ ទន**	អត្តលេខ ០៦៥២	វរអគ្គានុរក្សថ្នាក់លេខ១
៣- លោក **អ៊ឹម ឆុន្នី**	អត្តលេខ ១០២០	វរអគ្គានុរក្សថ្នាក់លេខ១
៤- លោក **ឆន សារ៉ែត**	អត្តលេខ ០៤១៩	វរអគ្គានុរក្សថ្នាក់លេខ១
៥- លោក **ផៃ ថា**	អត្តលេខ ០៤២០	វរអគ្គានុរក្សថ្នាក់លេខ១
៦- លោក **ចាប ញ៉ែន**	អត្តលេខ ១៣៣៨	វរអគ្គានុរក្សថ្នាក់លេខ១ ។

មាត្រា ២ .-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី គ្រប់ក្រសួង ប្រធានស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ចន្ទ ១ កើត ខែ ភទ្របទ ឆ្នាំរោង ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ សីហា ឆ្នាំ២០២១ ✓

ទីស្តីការគណៈរដ្ឋមន្ត្រី

ចាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៣
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:.ព.ស២៥៦៤.អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការនិយ័តកម្មក្របខ័ណ្ឌ តម្លើងឋានន្តរស័ក្តិ និងថ្នាក់ដល់មន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០០/០៩៦ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៨/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : និយ័តកម្មក្របខ័ណ្ឌ តម្លើងឋានន្តរស័ក្តិ និងថ្នាក់ដល់មន្ត្រីរាជការចំនួន ០៣រូប ដូចរាយនាមខាងក្រោម:

១-លោក **សៀង ប៊ុនឆឿន** ពីឋានន្តរស័ក្តិក្រមការ ថ្នាក់លេខ១ មកជាឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ។

២-លោកស្រី **ម៉ែន រស្មី** ពីឋានន្តរស័ក្តិក្រមការ ថ្នាក់លេខ៤ មកជាឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ។

៣-លោកស្រី **ឡាក់ សៅចាន់** ពីឋានន្តរស័ក្តិលេខាធិការរដ្ឋបាល ថ្នាក់លេខ៥ មកជាឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១ កើត ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ សីហា ឆ្នាំ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

អនុទទួលទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ណស/អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ ៖ តែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ទោ **អ៊ុក គឹមអធិការ** អគ្គលេខ ៥៧៩៧៨ ជាប្រធាននាយកដ្ឋានលិខិតឆ្លងដែន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ។

មាត្រា ២ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ អង្គារ ២ កើត ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៨៦ សសរ

សេចក្តីសម្រេច
ស្តីពី
ការផ្លាស់ប្តូរ និងបំពេញបន្ថែមសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ខេត្តស្វាយរៀង ខេត្តកំពង់ឆ្នាំង ខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ និងខេត្តកោះកុង ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត
- យោងសេចក្តីណែនាំលេខ ០១ សណន់ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី ខេត្ត ក្នុងការបំពេញបេសកកម្ម ដើម្បីត្រួតពិនិត្យ និងគាំទ្រកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

សម្រេច

ប្រការ១ ៖

ត្រូវបានផ្លាស់ប្តូរសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន**ខេត្តស្វាយរៀង ខេត្តកំពង់ឆ្នាំង ខេត្តឧត្តរមានជ័យ និងខេត្តបន្ទាយមានជ័យ** ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសមាសភាពខាងក្រោម៖

១. ឯកឧត្តម **ភួង សោភា** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ពីសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តស្វាយរៀង មកជាសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ឆ្នាំង។

២. ឯកឧត្តម **ចុង ផែត** អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ពីសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តឧត្តរមានជ័យ មកជាសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តបន្ទាយមានជ័យ។

ប្រការ២.-

ត្រូវបានបំពេញបន្ថែមសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន**ខេត្តឧត្តរមានជ័យ ខេត្តកោះកុង និងខេត្តស្វាយរៀង** ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសមាសភាពខាងក្រោម៖

១. ឯកឧត្តម **ជូ ជារិទ្ធ** អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ជាសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តឧត្តរមានជ័យ។

២. ឯកឧត្តម **ប៉ា វង្សសុក្រិត** អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ជាសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង។

៣. លោក **នួន ពេជ្រនិមិត្ត** អគ្គនាយករងបច្ចេកទេស ក្រសួងអភិវឌ្ឍន៍ជនបទ ជាសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តស្វាយរៀង។

ប្រការ៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋបាលខេត្តស្វាយរៀង រដ្ឋបាលខេត្តកំពង់ឆ្នាំង រដ្ឋបាលខេត្តឧត្តរមានជ័យ រដ្ឋបាលខេត្តបន្ទាយមានជ័យ រដ្ឋបាលខេត្តកោះកុង និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ និងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៩ កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០២១

នាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ស ខេង

កន្លែងទទួល:
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.ភាគល្អ...សហវ...ប្រកាស

ប្រកាសអន្តរក្រសួង
ស្តីពី
នីតិវិធីពិន័យអន្តរការណ៍ លើអំពើល្មើសនីតិច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៦ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម ក្រសួងយុត្តិធម៌ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ប្រការ១ ..

ប្រកាសអន្តរក្រសួងនេះ កំណត់អំពីនីតិវិធី និងសិទ្ធិក្នុងការពិន័យអន្តរការណ៍ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

ប្រការ២ ..

ប្រកាសអន្តរក្រសួងនេះ មានវិសាលភាពអនុវត្តចំពោះការពិន័យអន្តរការណ៍ លើអំពើល្មើសដែលមានចែងក្នុងមាត្រា៤១ មាត្រា៤៤ មាត្រា៤៥ មាត្រា៤៨ និងមាត្រា៤៩ នៃច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

ប្រការ៣ ..

មន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ «ក.ប.ប.» នៃក្រសួងពាណិជ្ជកម្ម ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ មានសមត្ថកិច្ចធ្វើការពិន័យអន្តរការណ៍ ចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

ប្រការ៤ ..

កម្រិតទឹកប្រាក់ពិន័យអន្តរការណ៍ ចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ត្រូវបានកំណត់ទៅតាមប្រភេទអំពើល្មើសនីមួយៗ ដោយអនុលោមតាមមាត្រា៤១ មាត្រា៤៤ មាត្រា៤៥ មាត្រា៤៨ និងមាត្រា៤៩ នៃច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

ប្រការ៥ ..

មន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន ក.ប.ប. មានភារកិច្ចដូចតទៅ៖

- ចេញកំណត់ត្រាស្តីពីបណ្ណពិន័យអន្តរការណ៍
- ចេញវិក្កយបត្របង់ប្រាក់ពិន័យអន្តរការណ៍ ទទួលប្រាក់ពិន័យអន្តរការណ៍ និងចេញបង្កាន់ដៃបង់ប្រាក់ឱ្យបុគ្គលល្មើស ក្នុងករណីទទួលប្រាក់ពិន័យអន្តរការណ៍ ដោយផ្ទាល់ជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ
- គ្រប់គ្រងវិក្កយបត្រ បង្កាន់ដៃបង់ប្រាក់ និងប្រាក់ចំណូលពីការពិន័យអន្តរការណ៍
- ចេញលិខិតជូនដំណឹងក្រើនរំលឹកចំពោះបុគ្គលល្មើស ឱ្យមកបង់ប្រាក់ពិន័យអន្តរការណ៍មិនឱ្យហួសកាលបរិច្ឆេទចុងក្រោយ ក្នុងករណីបុគ្គលនោះមិនបានបង់ប្រាក់ពិន័យក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ
- កសាងសំណុំរឿងទៅតាមនីតិវិធីច្បាប់ជាធរមានទៅតុលាការមានសមត្ថកិច្ច ក្នុងករណីបុគ្គលល្មើសមិនបានបង់ប្រាក់ពិន័យអន្តរការណ៍ នៅក្នុងរយៈពេលកំណត់ដូចមានចែងក្នុងប្រការ៦។

ប្រការ៦ ..

បុគ្គលល្មើស អាចបង់ប្រាក់ពិន័យអន្តរការណ៍ជូនមន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន ក.ប.ប. ភ្លាមៗ ឬយ៉ាងយូរ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលសាមីខ្លួនទទួលបានឯកសារពាក់ព័ន្ធនឹងការពិន័យអន្តរការណ៍ពីមន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន ក.ប.ប.។ ក្នុងករណីបុគ្គលល្មើសមិនបានបង់ប្រាក់ពិន័យអន្តរការណ៍ និងមិនបានដាក់ពាក្យបណ្តឹងតវ៉ានៅក្នុងរយៈពេលកំណត់ នោះមន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន ក.ប.ប. ត្រូវកសាងសំណុំរឿងតាមនីតិវិធីជាធរមាន ទៅតុលាការមានសមត្ថកិច្ច។

ប្រការ៧ ..

មន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន ក.ប.ប. អាចបញ្ជូនលិខិតជូនដំណឹង និងឯកសារពាក់ព័ន្ធនឹងការពិន័យអន្តរការណ៍ទៅគេហដ្ឋាន ទីស្នាក់ការ ឬទីតាំងនៃការធ្វើធុរកិច្ចដោយផ្ទាល់ ឬតាមសំបុត្រអនុសិដ្ឋដោយមានចុះហត្ថលេខាបានទទួល។

ក្នុងករណីដែលបុគ្គលល្មើសបដិសេធមិនព្រមទទួលលិខិតជូនដំណឹង និងឯកសារពាក់ព័ន្ធនឹងការពិន័យអន្តរការណ៍ ឬមិនមានម្ចាស់ ឬមិនមានតំណាងទទួលនោះ មន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន ក.ប.ប. ត្រូវបិទសេចក្តីជូនដំណឹងពីការពិន័យអន្តរការណ៍នៅគេហដ្ឋាន ទីស្នាក់ការ ឬទីតាំងនៃការធ្វើធុរកិច្ច និងនៅសាលាឃុំសង្កាត់។ បន្ទាប់ពីបានបិទផ្សាយរួច ឯកសារទាំងនោះត្រូវចាត់ទុកថាបានទទួលជាផ្លូវការដោយបុគ្គលល្មើស។

ប្រការ៨ ..

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់មន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន ក.ប.ប. មានសិទ្ធិប្តឹងទៅគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ «គ.ជ.ក.ប.» ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេចរបស់មន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន ក.ប.ប.។ គ.ជ.ក.ប. ត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃបានទទួលពាក្យបណ្តឹងតវ៉ានោះ។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ គ.ជ.ក.ប. មានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេចរបស់ គ.ជ.ក.ប.។

ប្រការ៩ ..

ប្រាក់ពិន័យដែលបានមកពីការពិន័យអន្តរការណ៍ ត្រូវកត់ត្រាជាចំណូលថវិការបស់ក្រសួងពាណិជ្ជកម្ម។

ប្រការ១០ ..

ក្រសួងពាណិជ្ជកម្ម ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈឱ្យបានទូលំទូលាយនូវខ្លឹមសារប្រកាសអន្តរក្រសួងនេះ និងត្រូវរៀបចំឱ្យមានកន្លែងទទួលពាក្យបណ្តឹងតវ៉ា ឬការមិនសុខចិត្តណាមួយ ចំពោះការពិន័យអន្តរការណ៍របស់មន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន ក.ប.ប.។

ប្រការ១១ ..

រាល់ការទទួលប្រាក់ចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ លើការពិន័យអន្តរការណ៍ចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបោះពុម្ពនិងបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ១២ ..

ក្រសួងពាណិជ្ជកម្ម ត្រូវរៀបចំគម្រោងចំណូលពីការពិន័យអន្តរការណ៍ទាក់ទងនឹងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ដោយមានមូលដ្ឋានគ្រោងគិតច្បាស់លាស់ និងគ្រោងចំណូលលម្អិតទៅតាមប្រភេទអំពើល្មើសនីមួយៗ ដើម្បីដាក់បញ្ចូលទៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

ក្រសួងពាណិជ្ជកម្ម ត្រូវទទួលខុសត្រូវប្រាក់កាសចំពោះប្រាក់ពិន័យអន្តរការណ៍ដែលប្រមូលបាន បង់ប្រាក់ចំណូល និងធ្វើសលាកបត្របង់ចំណូលថវិកាជាតិ ព្រមទាំងការចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងការកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

ប្រការ១៣ ..

ក្រសួងពាណិជ្ជកម្ម ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

របាយការណ៍ស្តីពីការអនុវត្តចំណូលពីការពិន័យអន្តរការណ៍ ចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ជាផ្នែកមួយនៃរបាយការណ៍រួមស្តីពីការអនុវត្តចំណូលរបស់ក្រសួងពាណិជ្ជកម្ម។

ប្រការ១៤ ..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ១៥ ..

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងពាណិជ្ជកម្ម ក្រសួងយុត្តិធម៌ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមការកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ២០២១

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | **រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** | **រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន | កើត រិទ្ធ | ប៉ាន សូរស័ក្តិ

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...សហវ...

ប្រកាសអន្តរក្រសួង
ស្តីពី
ការបែងចែកចំណូលពីការពិន័យអន្តរការណ៍ និងការពិន័យជាប្រាក់ លើអំពើល្មើសនីតិច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៦ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យ លេខ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញសេចក្តីសម្រេចលេខ១១៩ សសរ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ របស់រាជរដ្ឋាភិបាល ស្តីពីការប្រើប្រាស់ចំណូលមិនមែនសារពើពន្ធរបស់ក្រសួង ស្ថាប័នប្រមូលចំណូល សម្រាប់ការផ្តល់ការលើកទឹកចិត្តលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសអន្តរក្រសួងលេខ ...សហវ.ប្រក ចុះថ្ងៃទី...ខែ...ឆ្នាំ២០២១ ស្តីពីនីតិវិធីពិន័យអន្តរការណ៍ លើអំពើល្មើសនឹងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម ក្រសួងយុត្តិធម៌ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ប្រការ១ ..

ចំណូលពីការពិន័យអន្តរការណ៍ លើអំពើល្មើសនឹងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ដែលប្រមូលបានដោយក្រសួងពាណិជ្ជកម្ម ត្រូវបានបែងចែកដូចខាងក្រោម ៖

១- បង់ចូលថវិកាជាតិ ចំនួន ៤៩%(សែសិបប្រាំបួនភាគរយ) នៃប្រាក់ពិន័យអន្តរការណ៍ដែលប្រមូលបាន

២- ប្រាក់រង្វាន់លើកទឹកចិត្តរបស់ក្រសួងពាណិជ្ជកម្ម ចំនួន ៤៩%(សែសិបប្រាំបួនភាគរយ) នៃប្រាក់ពិន័យអន្តរការណ៍ដែលប្រមូលបាន

៣- ប្រាក់រង្វាន់លើកទឹកចិត្ត សម្រាប់បង់ចូលមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចំនួន ១%(មួយភាគរយ) នៃប្រាក់ពិន័យអន្តរការណ៍ដែលប្រមូលបាន

៤- ប្រាក់រង្វាន់លើកទឹកចិត្តរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១%(មួយភាគរយ) នៃប្រាក់ពិន័យអន្តរការណ៍ដែលប្រមូលបាន។

ប្រការ២ ..

ចំណូលប្រមូលបានពីការផ្តន្ទាទោសពិន័យជាប្រាក់ លើអំពើល្មើសនឹងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ដែលអនុវត្តតាមការសម្រេចរបស់តុលាការមានសមត្ថកិច្ច ត្រូវបានបែងចែកដូចខាងក្រោម៖

១- បង់ចូលថវិកាជាតិ ចំនួន ២៥%(ម្ភៃប្រាំភាគរយ) នៃប្រាក់ពិន័យដែលប្រមូលបាន

២- ប្រាក់រង្វាន់លើកទឹកចិត្តរបស់ក្រសួងពាណិជ្ជកម្ម ចំនួន ៤៩%(សែសិបប្រាំបួនភាគរយ) នៃប្រាក់ពិន័យដែលប្រមូលបាន

៣- ប្រាក់រង្វាន់លើកទឹកចិត្តរបស់សាលាជម្រះក្តីពាក់ព័ន្ធសរុប ចំនួន ២៤%(ម្ភៃបួនភាគរយ) នៃប្រាក់ពិន័យដែលប្រមូលបាន

៤- ប្រាក់រង្វាន់លើកទឹកចិត្ត សម្រាប់បង់ចូលមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចំនួន ១%(មួយភាគរយ) នៃប្រាក់ពិន័យដែលប្រមូលបាន

៥- ប្រាក់រង្វាន់លើកទឹកចិត្តរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១%(មួយភាគរយ) នៃប្រាក់ពិន័យដែលប្រមូលបាន។

ប្រការ៣ ៖

ប្រាក់រង្វាន់លើកទឹកចិត្តដែលផ្តល់ជូនក្រសួងពាណិជ្ជកម្ម សាលាជម្រះក្តីពាក់ព័ន្ធ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលកំណត់ក្នុងប្រការ១ និងប្រការ២ នៃប្រកាសអន្តរក្រសួងនេះ ត្រូវប្រើប្រាស់សម្រាប់ចំណាយឧបត្ថម្ភជូនមន្ត្រីដែលបំពេញការកិច្ចផ្ទាល់និងមន្ត្រីផ្សេងៗទៀត និងពង្រឹងយន្តការប្រមូលចំណូល។

ប្រការ៤ ៖

អនុញ្ញាតឱ្យក្រសួងពាណិជ្ជកម្ម បុរេប្រទានប្រាក់រង្វាន់លើកទឹកចិត្តពីចំណូលប្រមូលបានពីការពិន័យអន្តរការណ៍ លើអំពើល្មើសនឹងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ដែលរួមមាន ប្រាក់រង្វាន់របស់ក្រសួងពាណិជ្ជកម្ម ប្រាក់រង្វាន់សម្រាប់បង់ចូលមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅតាមការកំណត់ក្នុងប្រការ១ នៃប្រកាសអន្តរក្រសួងនេះ។

ប្រការ៥ ៖

ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តជូនមន្ត្រីរាជការ ត្រូវអនុវត្តដូចខាងក្រោម៖

ក. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងពាណិជ្ជកម្ម ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

គ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃសាលាជម្រះក្តី និងមន្ត្រីពាក់ព័ន្ធ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ប្រការ៦ ៖

ជារៀងរាល់ឆ្នាំ ក្រសួងពាណិជ្ជកម្ម ត្រូវរៀបចំគម្រោងចំណាយប្រាក់រង្វាន់លើកទឹកចិត្តសរុប ដោយផ្អែកតាមអត្រាប្រាក់រង្វាន់ និងឥណទានចំណូលប្រចាំឆ្នាំដែលបានគ្រោង ដើម្បីដាក់បញ្ចូលទៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

រាល់កិច្ចប្រតិបត្តិការចំណាយប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវកត់ត្រាឆ្លុះបញ្ចាំងនៅក្នុងថវិកាជាតិ ដូចកិច្ចប្រតិបត្តិការចំណាយដទៃទៀតរបស់ក្រសួងពាណិជ្ជកម្មដែរ។ ឥណទានចំណាយប្រាក់រង្វាន់ដែលបានគ្រោង ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់(អាណត្តិនិយ័តកម្ម) ដើម្បីទូទាត់ជាមួយប្រាក់រង្វាន់ដែលបានបុរេប្រទានពីចំណូលថវិកាជាតិ។

ប្រការ៧ ៖

ការទូទាត់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវធ្វើឡើងប្រចាំខែ ដោយអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

ក.ផ្នែកចំណូល

ក្រសួងពាណិជ្ជកម្ម ត្រូវធ្វើសំណើសុំកត់ត្រាចំណូល និងធ្វើសលាកបត្របង់ចំណូលថវិកាជាតិនូវទឹកប្រាក់រង្វាន់សរុបដែលបានបុរេប្រទាន រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល តារាងសម្រង់សលាកបត្របង់ចំណូលថវិកាជាតិ និងបណ្ណបង់ប្រាក់ តារាងស្តីពីការគណនាប្រាក់រង្វាន់ និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកបត្របង់ចំណូលថវិកាជាតិ។

ខ.ផ្នែកចំណាយ

ក្រសួងពាណិជ្ជកម្ម ត្រូវធ្វើសំណើសុំទូទាត់ចំណាយប្រាក់រង្វាន់សរុប និងធ្វើអាណត្តិបើកប្រាក់(អាណត្តិនិយ័តកម្ម) ដោយចុះចំនួនទឹកប្រាក់ស្មើនឹងទឹកប្រាក់បុរេប្រទាន ដែលបានចុះក្នុងសលាកបត្របង់ចំណូលថវិកាជាតិ។

ប្រការ៨ ៖

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៩ ៖

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងពាណិជ្ជកម្ម ក្រសួងយុត្តិធម៌ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៣ កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែមីនា ឆ្នាំ២០២១

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
កើត រិទ្ធ

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
ប៉ាន សូរស័ក្តិ

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
